# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្តីប្រចាំខែមេសា



លេខ ២៧០ ឆ្នាំទី២៣ ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២៣

Issue 270 Volume 23 Before Christ 2566 Common Era 2023

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- សារជូនពររបស់សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ........ ១
- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន២ ........ ៣
- ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី១០ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងកម្ពុជា និងឡាវ ........ ៤
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្តមនាយករដ្ឋមន្ត្រីម៉ាឡេស៊ី ........ ៦
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកអគ្គរដ្ឋទូតអូស្ត្រាលី ចូលជួបសម្តែងការគួរសម ........ ៨
- ព្រឹទ្ធសភា ប្រារព្ធពិធីសូត្រមន្តសុំសេចក្តីសុខ សិរីសួស្តី ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ........ ១១
- ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញសួរសុខទុក្ខនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៧០១ នៅខេត្តស្ទឹងត្រែង ........ ១២
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ........ ១៤


## សកម្មភាពគណៈកម្មការ




- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរឃុំចំនួន៥ ក្នុងស្រុកពញាក្រែក ........ ១៦
- សាស្ត្រាចារ្យ និស្សិត និងសមណនិស្សិត នៃសកលវិទ្យាល័យវេស្ទើន ចំនួន៩៧នាក់ អញ្ជើញទស្សនកិច្ចឈ្វេងយល់អំពីព្រឹទ្ធសភា ........ ១៨
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ........ ២០
- ការងារទទួលពាក្យបណ្តឹង ........ ២៣
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨ ........ ២៣
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ........ ២៤
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........ ៤៤


## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងត្រីមាសទី១ ២០២៣ ព្រមទាំងលើកទិសដៅការងារបន្ត ........ ៤៦
- ឯកឧត្តម អ៊ុំ សារឹទ្ធ អនុញ្ញាតឱ្យនិស្សិតជ័យលាភីអាហារូបករណ៍អូស្ត្រាលី ចូលជួបសំណេះសំណាល និងទទួលអនុសាសន៍ ........ ៤៨
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ........ ៥០



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម អ៊ុំ សារឹទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម លីម ប៊ុនហុក

ឯកឧត្តម កែវ ចាន់ណា

ឯកឧត្តម សុខ រិទ្ធី

ឯកឧត្តម ជួន ណា

ឯកឧត្តម គឹម ពិសិដ្ឋ

លោក ជួន សុខជី

លោក ទេព មករា

លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

លោកស្រី សុខ សុជាតា

លោក គិន ប៉ាត់ថាមីរ


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រី នៃប្រទេសម៉ាឡេស៊ី។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅកោះសូទិន ខេត្តកំពង់ចាម។*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**

**E-mail : oumsarith.sgsenate@gmail.com**

**Website: www.senate.gov.kh**

**www.elibrary.senate.gov.kh**

**Facebook: www.facebook.com/senateofcambodia**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**



## សារជូនពរ

## របស់សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

- សូមក្រាបថ្វាយបង្គំសម្ដេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្ដេចព្រះរាជាគណៈ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- សូមក្រាបបង្គំទូលថ្វាយសម្ដេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈ
- សម្ដេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្ដម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី ជាទីគោរពស្នេហា
- បងប្អូនជនរួមជាតិ ជាទីគោរពរាប់អាន!

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមចូលរួមអបអរសាទរក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ដែលប្រព្រឹត្តទៅនាថ្ងៃសុក្រ ៩រោច ថ្ងៃសៅរ៍ ១០រោច និងថ្ងៃអាទិត្យ ១១រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ពុទ្ធស័ករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ថ្ងៃទី១៥ និងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ ជាមួយនឹងជនរួមជាតិទាំងអស់ដែលកំពុងនៅក្នុង និងក្រៅប្រទេស សូមទទួលបានពរជ័យ សិរីសួស្ដី ជ័យមង្គល បវរមហាប្រសើរ វិបុលសុខគ្រប់ប្រការ ក្នុងក្រុមគ្រួសារ និងសង្គមជាតិទាំងមូល។

មហាសង្ក្រាន្តបីថ្ងៃនេះ ជាឱកាសឱ្យប្រជាពលរដ្ឋយើងរួមគ្នាជម្រុះចោលឱ្យជ្រះស្រឡះនូវភាពអពមង្គលឧបទ្រពចង្រៃ និងមន្ទិលហ្មងសៅទាំងពួងក្នុងឆ្នាំចាស់ ហើយតាំងចិត្តថ្មីប្រព្រឹត្តអំពើល្អប្រកបដោយមេត្តា ករុណា មុទិតា ឧបេក្ខា និងបញ្ញាចាប់ពីឆ្នាំថ្មីនេះតទៅ។

ក្រោមម្លប់ដ៏ត្រជាក់ត្រជុំ នៃព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្រោមដំបូល នៃរដ្ឋធម្មនុញ្ញ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា និងលើមូលដ្ឋាន នៃមហាសាមគ្គី ឯកភាពជាតិរឹងមាំ ដំណើរទៅមុខរបស់ជាតិយើងប្រព្រឹត្តទៅដោយរលូន និងមានជោគជ័យជាបន្តបន្ទាប់។

នៅក្នុងឆ្នាំ២០២២ កម្ពុជាយើងសម្រេចបានលទ្ធផលវិជ្ជមានគួរជាទីមោទនៈ ទាំងការរក្សាសន្តិភាព ស្ថេរភាព សន្តិសុខ សុវត្ថិភាពសង្គម ទាំងការលើកស្ទួយជីវភាពប្រជាជន ទាំងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងទាំងការរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងការរៀបចំ ការដឹកនាំ និងការចូលរួមកិច្ចប្រជុំអន្តរជាតិនានា ជាពិសេសកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និងទី៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ព្រមទាំងមហាន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ ដែលកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ។

ឆ្លៀតក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនប្រទេសជាមិត្តភក្តិជិតឆ្ងាយ ស្ថាប័ន អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដែលបានលើកទឹកចិត្ត និងជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិ និងប្រជាពលរដ្ឋកម្ពុជា។

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាឆ្នាំថ្មី និងព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ សូមទ្រង់ព្រះមេត្តាជួយប្រោះព្រំសព្ទសាធុការពរ បវរមហាប្រសើរ ថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈ សូមព្រះអង្គមានព្រះជន្មយឺនយូរជាងរយព្រះវស្សា ព្រះសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំ នៃប្រជារាស្ត្រខ្មែរគ្រប់ៗរូបជារៀងដរាប។

ជាមួយគ្នានេះដែរ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាឆ្នាំថ្មី ថ្វាយសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ថ្វាយ និងប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងសូមប្រសិទ្ធពរ បវរមហាប្រសើរ ថ្វាយសម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ជូនសម្តេច ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និយោជក និយោជិត កម្មករ កសិករ ពាណិជ្ជករ អាជីវករ ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ជនរួមជាតិក្នុង និងក្រៅប្រទេស សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមទេវតាឆ្នាំថ្មី ព្រះនាម **កិមិរាទេវី** ជួយអភិបាលគ្រប់គ្រងថែរក្សា ជួយបីបាច់ថែរក្សាគាំពារ និងប្រសិទ្ធពរជ័យ សិរីសួស្តីដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ឱ្យមានសមានចិត្តជាកុសល យោគយល់គ្នាសន្តោសប្រណី រួបរួមសាមគ្គីជាមហាគ្រួសារតែមួយនៅលើទឹកដីមាតុភូមិអង្គរជាទីស្នេហា ដោយក្តីសុខក្សេមក្សាន្ត កិត្តិយស និងសេចក្តីថ្លៃថ្នូរតរៀងទៅ៕

ឆ្នាំថ្មី ឱកាសថ្មី វិញ្ញាសាថ្មី ការខិតខំថ្មី ជោគជ័យថ្មី !

# សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន២



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាថ្ងៃសុក្រ ទី៧ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង៨:០០ នាទីព្រឹក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានប្រជុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន២ រួមមាន៖

**១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការ មហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិ-ការកិច្ច និងមុខងារសាធារណៈ នៃព្រឹទ្ធសភា សុំដាក់សេចក្តី ព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវ ទៅក្នុងរបៀបវារៈសម័យ ប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។**

**២-កំណត់របៀបវារៈ និងកាលបរិច្ឆេទ បន្តសម័យប្រជុំ លើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។**

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការ-អចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃចន្ទ ទី១០ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបន្តសម័យ ប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤ ដោយមានរបៀប-វារៈតែមួយគឺ៖ ពិនិត្យ ហើយឱ្យយោបល់សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិប-តេយ្យប្រជាមានិតឡាវ៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គង់ យ៉ារីន)





*ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី១០ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងកម្ពុជា និងឡាវ




*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤*

នាព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង៨:០០ នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី១០ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលមានវត្តមានសមាជិកព្រឹទ្ធសភាចំនួន៥៨រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈតែមួយគឺ **ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។**

ក្នុងឱកាសនោះ ឯកឧត្ដម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញឡើងធ្វើសេចក្ដីរាយការណ៍ជូនអង្គប្រជុំជ្រាបអំពី លទ្ធផល នៃការពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់នេះ ដែលត្រូវបានតាក់តែងឡើងក្នុង



*ឯកឧត្ដម សុខ ឥសាន ឡើងអានរបាយការណ៍ជូនអង្គប្រជុំ*



*ទិដ្ឋភាពបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤*

គោលបំណងកសាងខ្សែព្រំដែនសន្តិភាព ស្ថិរភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍយូរអង្វែងឈរលើមូលដ្ឋាននៃការគោរពឯករាជ្យ អធិបតេយ្យភាព និងបូរណភាពដែនដីគ្នា គោរពផលប្រយោជន៍គ្នាទៅវិញទៅមកដើម្បីបង្កើនឥតឈប់នូវទំនាក់ទំនងជិតខាងល្អ សាមគ្គីភាពជាប្រពៃណី រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងការខិតខំបោះបង្គោលព្រំដែន។

សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ គឺជាកំណត់ត្រាទទួលយកលទ្ធផលនៃការត្រួតពិនិត្យខ្សែព្រំដែនរួមប្រមាណជា៨៦% ដែលប្រទេសទាំងពីរសម្រេចបានលើការងារព្រំដែនដែលត្រូវបានប្រមុខរដ្ឋាភិបាល នៃប្រទេសទាំងពីរ (កម្ពុជា-ឡាវ) បានចុះហត្ថលេខា នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ នៅរដ្ឋធានីវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវកន្លងទៅ។

សន្ធិសញ្ញានេះ ក៏ជាឯកសារផ្លូវច្បាប់ប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់បំផុតមួយ ដែលព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានចុះហត្ថលេខាទទួលស្គាល់ជាផ្លូវការលើខ្សែព្រំដែនដែលអាណានិគមបានបន្សល់ទុកឱ្យ បន្ទាប់ពីប្រទេសទាំងពីរទទួលបានឯករាជ្យដែលជាឯកសារផ្លូវការមូលដ្ឋានដ៏សំខាន់បំផុត ក្នុងការបន្តរកដំណោះស្រាយតំបន់ព្រំដែននៅសល់ប្រមាណជាង១៤%ទៀត ដែលភាគីទាំងពីរមិនទាន់សម្រេចបាន និងជាឯកសារគ្រឹះការពារបានបូរណភាពទឹកដីកម្ពុជា ដោយមានខ្សែព្រំដែនមួយច្បាស់លាស់។

សេចក្ដីព្រាងច្បាប់នេះ ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមចំនួន១០៥សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦។



*ឯកឧត្តម វ៉ា គឹមហុង ឡើងស្រាយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា*

ក្រោយពីសមាជិកព្រឹទ្ធសភាបានឡើងមានយោបល់រួចមក ឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន និងជាប្រធានគណៈកម្មការចម្រុះកិច្ចការព្រំដែន បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៨សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ ទេព មករា រូបភាព៖ គង់ យ៉ារីន)





*ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តលើសេចក្ដីព្រាងច្បាប់*

# សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្តមនាយករដ្ឋមន្ត្រីម៉ាឡេស៊ី



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ និង
ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម*

នារសៀលថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១៤:០០នាទី នៅវិមានព្រឹទ្ធសភា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលឯកឧត្តម **ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** (Dato' Seri Anwar bin Ibrahim) នាយករដ្ឋមន្ត្រី នៃប្រទេសម៉ាឡេស៊ី ចូលជួបសម្តែងការគួរសម ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូ អញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមប្រជាជនកម្ពុជា ព្រឹទ្ធសភា និងខ្លួនសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងនូវការស្វាគមន៍ដ៏កក់ក្តៅចំពោះឯកឧត្តមនាយករដ្ឋមន្ត្រី និងលោកជំទាវ ព្រមទាំងគណៈប្រតិភូដែលបានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។ ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនាពេលនេះ ពិតជាមានសារៈសំខាន់ដល់ការពង្រឹងពង្រីកចំណងមិត្តភាព កិច្ចសហប្រតិបត្តិការដ៏ល្អដែលមានស្រាប់រវាងប្រទេស និងប្រជាជនទាំងពីរ និងបន្តថែរក្សាពូនជ្រំទំនាក់ទំនងដ៏ល្អនេះឱ្យស្ថិតស្ថេររឹងមាំយូរអង្វែង ហើយនាំមកនូវផលប្រយោជន៍ទៅវិញទៅមកដ៏ធំធេងសម្រាប់ប្រជាជន និងប្រទេសទាំងពីរ ទាំងក្នុងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងឱកាសនោះ ឯកឧត្តមនាយករដ្ឋមន្ត្រីបានថ្លែងអំណរគុណចំពោះសម្តេចប្រធានព្រឹទ្ធសភា ដែលបានចំណាយពេលវេលាដ៏មានតម្លៃទទួលជួបគណៈប្រតិភូនាពេលនេះ។ ឯកឧត្តមបានជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភាជ្រាបថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ នៅព្រះរាជាណាចក្រកម្ពុជានាពេលនេះ គឺដើម្បីឈ្វេងយល់អំពីការរីកចម្រើន និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក ព្រមទាំងដើម្បីពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ។

ជាមួយគ្នានោះ ឯកឧត្តមនាយករដ្ឋមន្ត្រីបានថ្លែងនូវការកោតសរសើរចំពោះបទពិសោធន៍ដ៏ល្អរបស់កម្ពុជា ចំពោះការបើកទូលាយលើជំនឿសាសនានៅព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមគ្នានោះ សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការអបអរសាទរចំពោះការសម្រេចនូវសមិទ្ធផលសង្គមសេដ្ឋកិច្ចដ៏ស្ងប់ស្ងែងរបស់ប្រជាជន និងប្រទេសម៉ាឡេស៊ី។





*ទិដ្ឋភាពរួមក្នុងពិធីជួបសម្តែងការគួរសម*

សម្ដេចមានជំនឿថា ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រ និងថ្នាក់ដឹកនាំម៉ាឡេស៊ី ម៉ាឡេស៊ីនឹងបន្តសម្រេចបានជោគជ័យក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយវិបុលភាព វឌ្ឍនភាព និងសុភមង្គល។ កម្ពុជាចាត់ទុកការរីកចម្រើនរបស់ម៉ាឡេស៊ី ជាការរីកចម្រើនរួមរបស់សហគមន៍អាស៊ាន។

សម្ដេចប្រធានព្រឹទ្ធសភាបានវាយតម្លៃខ្ពស់ និងមានសេចក្ដីពេញចិត្តជាខ្លាំងចំពោះការរីកចម្រើនជាបន្តបន្ទាប់រវាងប្រទេសទាំងពីរ ក្នុងក្របខ័ណ្ឌ នៃទំនាក់ទំនងទ្វេភាគី និងពហុភាគី លើវិស័យសំខាន់ៗ ដូចជា៖ នយោបាយ សេដ្ឋកិច្ច វិនិយោគ ពាណិជ្ជកម្ម ទេសចរណ៍ ទូរគមនាគមន៍ រ៉ែ និងថាមពល អប់រំ ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ការផ្លាស់ប្ដូររវាងប្រជាជន និងប្រជាជន ការផ្លាស់ប្ដូរទស្សនកិច្ចទៅវិញទៅមកជាញឹកញាប់រវាងឥស្សរជនគ្រប់លំដាប់ថ្នាក់ និងគាំទ្រគ្នាទៅវិញទៅមកនៅក្នុងក្របខ័ណ្ឌ កិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិនានា ជាពិសេសក្នុងក្របខ័ណ្ឌអាស៊ាន និងអង្គការសហប្រជាជាតិ។

សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវសេចក្ដីរីករាយចំពោះទំហំវិនិយោគ និងការផ្លាស់ប្ដូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរមានកំណើនល្អប្រសើរជាបន្តបន្ទាប់។ ព្រឹទ្ធសភាសូមលើកទឹកចិត្តដល់រដ្ឋាភិបាលទាំងពីរពិនិត្យសក្ដានុពលឱ្យអស់លទ្ធភាពក្នុងការបង្កើនការផ្លាស់ប្ដូរពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរបន្ថែមទៀត ដើម្បីនាំមកនូវកំណើនសេដ្ឋកិច្ចរួម និងវិបុលភាពសម្រាប់ប្រជាជនទាំងពីរ និងដើម្បីទប់ស្កាត់ផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចសកល។ ព្រឹទ្ធសភាបច្ចុប្បន្ន ក៏ដូចទៅអនាគតបន្តគាំទ្ររាល់គម្រោងសហប្រតិបត្តិការ និងយន្តការទ្វេភាគីនានា ដែលបានធ្វើឡើងរវាងរដ្ឋាភិបាលទាំងពីរ ដើម្បីនាំមកនូវសន្តិភាព ស្ថិរភាព ការអភិវឌ្ឍសម្រាប់ប្រទេសទាំងពីរ សម្រាប់តំបន់ និងអន្តរជាតិ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់លើសេរីភាពខាងជំនឿសាសនា។ នាពេលបច្ចុប្បន្ននេះ ឥស្លាមសាសនាជាសាសនាធំទី២ នៅកម្ពុជា។ មានសាសនិកឥស្លាមជាច្រើនរូប ត្រូវបានផ្ដល់តួនាទីនៅក្នុងជួររាជរដ្ឋាភិបាល ជាតំណាងរាស្ត្រ និងជាសមាជិកព្រឹទ្ធសភា។ នៅកម្ពុជាពុំមានទំនាស់សាសនាទេ មានសុខដុមនីយកម្មផ្នែកសាសនា ហើយត្រូវបានផ្ដល់សិទ្ធិ និងឱកាសស្មើៗគ្នាក្នុងសង្គម។

តាមរយៈឯកឧត្ដមនាយករដ្ឋមន្ត្រី សម្ដេចប្រធានព្រឹទ្ធសភាបានផ្ដាំផ្ញើសួរសុខទុក្ខដោយសេចក្ដីគោរពជូនឯកឧត្ដមប្រធានព្រឹទ្ធសភាម៉ាឡេស៊ី។ ព្រឹទ្ធសភាកម្ពុជាមានបំណងបង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងព្រឹទ្ធសភាម៉ាឡេស៊ីក្នុងការជំរុញការបង្កើតក្រុមមិត្តភាពរវាងព្រឹទ្ធសភា នៃប្រទេសទាំងពីរ ការជួយគាំទ្រគ្នាទៅវិញទៅមក ក្នុងក្របខ័ណ្ឌអន្តរសភា។ ជាមួយគ្នានោះ សម្ដេចបានគោរពអញ្ជើញឯកឧត្ដមប្រធានព្រឹទ្ធសភាម៉ាឡេស៊ី មកបំពេញទស្សនកិច្ចជាផ្លូវការនៅកម្ពុជាក្នុងពេលវេលាសមស្របណាមួយ។ សម្ដេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនឯកឧត្ដមនាយករដ្ឋមន្ត្រីនិងគណៈប្រតិភូមានសុខភាពល្អ និងទទួលបាននូវជោគជ័យ ក្នុងការបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្ដម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម នាយករដ្ឋមន្ត្រី នៃប្រទេសម៉ាឡេស៊ី*

# សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកអគ្គរដ្ឋទូតអូស្ត្រាលី ចូលជួបសម្តែងការគួរសម




*សម្តេចវិបុលសេនាភក្តី សាយ ឈុំ និងឯកឧត្តម ចាស្ទីន ខេវិន វ៉ាយអេត*

នាព្រឹកថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣ នាវេលាម៉ោង៨:៤០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលឯកឧត្តម **ចាស្ទីន ខេវិន វ៉ាយអេត** (Justin Kevin Whyatt) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនៅវិមានព្រឹទ្ធសភា។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការស្វាគមន៍ និងអបអរសាទរចំពោះឯកឧត្តម **ចាស្ទីន ខេវិន វ៉ាយអេត** ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា។ សម្តេចមានជំនឿជឿជាក់ថា ក្នុងអាណត្តិបេសកកម្មការទូតរបស់ឯកឧត្តម **ចាស្ទីន ខេវិន វ៉ាយអេត** ឯកឧត្តមនឹងបន្តថែរក្សាទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អដែលមានស្រាប់ និងបន្តខិតខំជំរុញបន្ថែមទៀត នៃទំនាក់ទំនងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរជាងនេះថែមទៀត ដើម្បីនាំមកនូវគុណប្រយោជន៍ដ៏ធំធេង សម្រាប់ប្រជាជនកម្ពុជា និងប្រជាជនអូស្ត្រាលីទាំងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត។

ក្នុងឱកាសនោះ ឯកឧត្តម **ចាស្ទីន ខេវិន វ៉ាយអេត** បានសម្តែងនូវសេចក្តីរីករាយដែលបានមកបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា ហើយឯកឧត្តមធ្លាប់បានបម្រើការងារនៅស្ថានទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជាអស់រយៈពេល២០ឆ្នាំកន្លងមកហើយ។ ឆ្នាំនេះគឺជាលើកទី២របស់ឯកឧត្តមដែលមកបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសមួយមានប្រវត្តិសាស្ត្រដ៏យូរលង់ណាស់មកហើយ និងមានវប្បធម៌ដ៏សម្បូរបែប មានប្រាសាទអង្គរវត្តដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានវាយតម្លៃខ្ពស់ចំពោះការអភិវឌ្ឍ និងរីកចម្រើនរបស់ប្រទេសកម្ពុជាក្នុងរយៈពេលជាង ១៥ឆ្នាំកន្លងទៅនេះ លើវិស័យការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ជាពិសេសការអភិវឌ្ឍទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ។ ជាមួយគ្នានោះ ឯកឧត្តមបានសម្តែងនូវការអបអរសាទរចំពោះប្រទេសកម្ពុជា ដែលទទួលបានជោគជ័យក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ ទី៤១ និងកិច្ចប្រជុំពាក់ព័ន្ធ ព្រមទាំងការរៀបចំមហា-





ទិដ្ឋភាពរួមក្នុងពិធីជួបសម្តែងការគួរសម

សន្និបាតអន្តរសភាអាស៊ានលើកទី៤៣។ ហើយក្នុងអំឡុងនៃវិកវាលដាលនៃជំងឺកូវីដ-១៩ ប្រទេសកម្ពុជាបានគ្រប់គ្រងជំងឺកូវីដ-១៩បានយ៉ាងល្អ ដោយមានការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋចាប់ពីអាយុ៣ឆ្នាំឡើងទៅ។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានបញ្ជាក់ថា ប្រទេសទាំងពីរមានការផ្លាស់ប្តូរដំណើរទស្សនកិច្ចគ្នាទៅវិញទៅមក រវាងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃប្រទេសទាំងពីរ។ ក្នុងនោះក៏មានដំណើរទស្សនកិច្ច និងចូលរួមកិច្ចប្រជុំនានាពីសមាជិកសភាអូស្ត្រាលី មកកាន់ប្រទេសកម្ពុជាផងដែរ។

ឯកឧត្តមឯកអគ្គរដ្ឋទូត បានប្រសិទ្ធពរជូនប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកីឡាស៊ីហ្គេម ប៉ារ៉ាហ្គេមលើកទី៣២ និងការរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៧ ឱ្យទទួលបានជោគជ័យ។

ឯកឧត្តមឯកអគ្គរដ្ឋទូតមានជំនឿថា តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តម ឯកឧត្តមនឹងខិតខំរួមចំណែកក្នុងការពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងសភា រដ្ឋាភិបាល និងប្រជាជន នៃប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត។ ជាមួយគ្នានោះ ឯកឧត្តមនឹងខិតខំរួមចំណែកក្នុងការលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ លើវិស័យកសិកម្ម ធុរកិច្ច ពាណិជ្ជកម្ម សុខាភិបាល អប់រំ និងវិស័យដោះមីន។

ក្នុងនាមប្រជាជនកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណ និងដឹងគុណចំពោះ



ទិដ្ឋភាពរួមក្នុងពិធីជួបសម្តែងការគួរសម

រដ្ឋាភិបាលអូស្ត្រាលី ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សះផ្សាបង្រួបបង្រួមជាតិ និងការស្វែងរកសន្តិភាពជូនប្រជាជនកម្ពុជា។ ជាមួយគ្នានោះ សម្តេចក៏បានអរគុណដ៏ជ្រាលជ្រៅចំពោះប្រជាជន និងរដ្ឋាភិបាលអូស្ត្រាលី ដែលបានផ្តល់ជំនួយដ៏ថ្លៃថ្លាដល់កម្ពុជា រួមមាន៖ ជំនួយអភិវឌ្ឍន៍ផ្លូវការលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ពាណិជ្ជកម្ម កសិកម្ម នេសាទ ធនធានទឹក អភិបាលកិច្ច អប់រំ សុខាភិបាល។ ការផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិត បណ្ឌិត សម្រាប់និស្សិត និងមន្ត្រីរាជការកម្ពុជា ទៅសិក្សានៅប្រទេសអូស្ត្រាលី។ ជំនួយក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងដំណើរការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩។

សម្តេចប្រធានព្រឹទ្ធសភាបានរំលឹកអំពីទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និងប្រទេសអូស្ត្រាលី ដែលមានប្រវត្តិទំនាក់ទំនងជាយូរលង់ណាស់មកហើយ។ ទំនាក់ទំនងដ៏ល្អនេះ ត្រូវបានថែរក្សាពូនជ្រំរហូតមកដល់បច្ចុប្បន្ន។ ឆ្នាំ២០២២កន្លងទៅនេះ ប្រទេសទាំងពីរបានប្រារព្ធខួបអនុស្សាវរីយ៍លើកទី៧០ នៃថ្ងៃបង្កើតទំនាក់ទំនងការទូតដ៏ឱឡារិក និងប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅ។

សម្តេចប្រធានព្រឹទ្ធសភាបានកត់សម្គាល់ដោយសេចក្តីរីករាយចំពោះការកើនឡើង នៃការផ្លាស់ប្តូរពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរមានការកើនឡើងជានិច្ច។ ជាមួយគ្នានោះ សម្តេចបានស្នើឯកឧត្តមឯកអគ្គរដ្ឋទូតជួយចលនាលើកទឹកចិត្តអ្នកវិនិយោគ និងអ្នកទេសចរអូស្ត្រាលីមកបណ្តាក់ទុនវិនិយោគ និងទស្សនាកម្ពុជាឱ្យកាន់តែច្រើនបន្ថែមទៀត។

សម្តេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ព្រឹទ្ធសភាកម្ពុជា និងព្រឹទ្ធសភាអូស្ត្រាលីមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អជាមួយគ្នា ដោយបានផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមក និងគាំទ្រគ្នានៅក្នុងក្របខ័ណ្ឌអន្តរសភា។ ជាមួយគ្នានោះព្រឹទ្ធសភាកម្ពុជាក៏បានបង្កើតក្រុមមិត្តភាពជាមួយនឹងសភាអូស្ត្រាលីផងដែរ។

ក្នុងនាមព្រឹទ្ធសភា សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណដល់រដ្ឋាភិបាល ក៏ដូចជាសភាអូស្ត្រាលី ដែលបានផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិត និងវគ្គបណ្តុះបណ្តាលកិច្ចការសភាដល់មន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា និងមន្ត្រីសភាកម្ពុជា នៅប្រទេសអូស្ត្រាលី។ តាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូត សម្តេចបានស្នើឯកឧត្តមជួយជំរុញឱ្យព្រឹទ្ធសភាអូស្ត្រាលីបន្តផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជាលើកិច្ចការសភា នៅព្រឹទ្ធសភាអូស្ត្រាលី។

សម្តេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ព្រឹទ្ធសភាត្រៀមខ្លួនជានិច្ច ដើម្បីធ្វើសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងឯកឧត្តមឯកអគ្គរដ្ឋទូត ក៏ដូចជាស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងសម្រាប់ប្រទេស និងប្រជាជនទាំងពីរ។

សម្តេចប្រធានព្រឹទ្ធសភា បានប្រសិទ្ធពរជូនឯកឧត្តមឯកអគ្គរដ្ឋទូត មានសុខភាពល្អបរិបូរណ៍ និងទទួលបានជោគជ័យក្នុងការបំពេញបេសកកម្មការទូតដ៏ខ្ពង់ខ្ពស់នៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ថតរូបអនុស្សាវរីយ៍ជាមួយ ឯកឧត្តម ចាស្ទីន ខេវិន វ៉ាយអេត*

# ព្រឹទ្ធសភា ប្រារព្ធពិធីសូត្រមន្តសុំសេចក្តីសុខ សិរីសួស្តី ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា (ឆ្វេង)
និងឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន (ស្តាំ)*

ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ដែលខិតជិតចូលមកដល់នាពេលខាងមុខនេះ នាព្រឹកថ្ងៃសុក្រ ទី៧ ខែមេសា ឆ្នាំ២០២៣ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធពិធីសូត្រមន្តអបអរសាទរឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដើម្បីសុំសេចក្តីសុខ សិរីសួស្តី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា និងឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា ព្រមទាំងសមាជិក សមាជិកាព្រឹទ្ធសភា ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ក្នុងពិធីសូត្រមន្តនេះ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញថ្វាយនូវគ្រឿងសក្ការៈបូជា ទៀន ធូប ផ្កាភ្ញី និងប្រារព្ធកិច្ចនមស្ការព្រះរតនត្រ័យ សមាទានសីល និមន្តព្រះសង្ឃសូត្រព្រះធម៌ស្វាធ្យាយ ចម្រើនព្រះបរិត្ត និងពុទ្ធជ័យមង្គល ព្រមទាំងប្រគេនចង្ហាន់ ទេយ្យទាន និងគ្រឿងបរិក្ខារផ្សេងៗ វេរប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសមហាកុសលផលបុណ្យជូនដល់ដួងវិញ្ញាណក្ខន្ធញាតិទាំងប្រាំពីរសន្តាន ឥស្សរជន និងយុទ្ធជនដែលបានពលីជីវិត ដើម្បីជាតិមាតុភូមិ ជាពិសេសដល់ដួងវិញ្ញាណក្ខន្ធរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជាស៊ីម** សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស** និងឯកឧត្តម **នៃ ប៉េណា** ដែលបានទទួលមរណកាលទៅកាន់លោកខាងមុខ។

បន្ទាប់ពីពិធីសូត្រមន្តតាមទំនៀមទម្លាប់ប្រពៃណី ព្រះពុទ្ធសាសនាបានចប់សព្វគ្រប់រួចមក ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទស្សនាការសម្តែងរបាំត្រុដិ ព្រមទាំងមានការលេងល្បែងប្រជាប្រិយខ្មែរជាច្រើនយ៉ាងសប្បាយរីករាយ។

សូមជម្រាបថា ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ នឹងប្រព្រឹត្តទៅនាថ្ងៃសុក្រ ៩រោច ថ្ងៃសៅរ៍១០រោច និងថ្ងៃអាទិត្យ១១រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ពុទ្ធស័ករាជ២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ថ្ងៃទី១៥ និងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ ដែលមានទេវតាឆ្នាំថ្មី ព្រះនាមកិមិរាទេវី៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)



*ទិដ្ឋភាពក្នុងពិធីសូត្រមន្តក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ*

# ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញសួរសុខទុក្ខនគរបាល វរសេនាតូចការពារព្រំដែនគោកលេខ៧០១ នៅខេត្តស្ទឹងត្រែង




*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន សំណេះសំណាលជាមួយ វរសេនាតូចការពារព្រំដែនគោកលេខ៧០១*

នាព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយជូនដល់កងកម្លាំងនគរបាលការពារព្រំដែនកម្ពុជា-ឡាវ នៃវរសេនាតូចការពារព្រំដែនគោកលេខ៧០១ ចំនួន១៦៦ នាក់ ស្ថិតនៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបូរីអូរស្វាយ-មានជ័យ ខេត្តស្ទឹងត្រែង។

ក្នុងឱកាសនោះ លោកឧត្តមសេនីយ៍ត្រី **ចាន់ សុផា** ស្នងការរងផែននគរបាលការពារព្រំដែនគោក នៃស្នងការនគរបាលខេត្តស្ទឹងត្រែង បានឡើងធ្វើសេចក្តីរាយការណ៍សង្ខេបអំពីលក្ខណៈភូមិសាស្ត្រ រចនាសម្ព័ន្ធ ការចាត់តាំងអនុវត្ត សភាពការណ៍ និងលទ្ធផលការងារការពារព្រំដែន (កម្ពុជា-ឡាវ)ដែលសម្រេចបាននាពេលកន្លងមក ព្រមទាំងលើកឡើងអំពីបញ្ហាប្រឈម និងសំណូមពរមួយចំនួនជូនគណៈប្រតិភូជួយដោះស្រាយ ដើម្បីងាយស្រួលក្នុងការប្រតិបត្តិការ និងទប់ស្កាត់បទល្មើសផ្សេងៗនៅតាមខ្សែបន្ទាប់ព្រំដែន។

មានមតិសំណេះសំណាលនាឱកាសនោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានពាំនាំនូវប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភាជូនចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងកងកម្លាំនគរបាលការពារវរសេនាតូចព្រំដែនគោកលេខ៧០១ ព្រមទាំងរំលឹកអំពីការចងសម្ព័ន្ធមេត្រីភាពរវាងព្រឹទ្ធសភា និងវរសេនាតូចការពារព្រំដែនលេខ៧០១ ដែលតែងតែមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អំពីសុខទុក្ខ និងការលំបាករបស់កងកម្លាំងអាជ្ញាធរមានសមត្ថកិច្ចនៅតាមបណ្តោយព្រំដែន ជាពិសេសកងកម្លាំងនគរបាលការពារព្រំដែនកម្ពុជា-ឡាវ នៃវរសេនាតូចការពារព្រំដែនគោកលេខ៧០១។

ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានមានប្រសាសន៍ សូមទោសចំពោះការខកខានមិនបានមកសួរសុខទុក្ខបងប្អូននគរបាលវរសេនាតូចការពារព្រំដែលគោកលេខ៧០១ គឺដោយសារតែប្រទេសជាតិជួបប្រទះនូវការរីករាលដាល នៃជំងឺកូវីដ-១៩។ ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានបញ្ជាក់ថា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិត





*ទិដ្ឋភាពកងកម្លាំងនគរបាលការពារព្រំដែនចូលរួមក្នុងពិធីជួបសំណេះសំណាល*



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ឡើងមានប្រសាសន៍សំណេះសំណាល*

របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ធ្វើឱ្យរាជរដ្ឋាភិបាលគ្រប់គ្រងជំងឺកូវីដ-១៩បានយ៉ាងល្អ។ ជាមួយគ្នានោះ កម្ពុជាបានបើកដំណើរការពេញលេញសង្គម-សេដ្ឋកិច្ចតាមគន្លងប្រក្រតីភាពថ្មី។ ចំពោះបញ្ហាព្រំដែនជាមួយនឹងប្រទេសជិតខាងសម្តេចតែងតែគិតគូរគ្រប់ពេលវេលា នឹងត្រូវបានដោះស្រាយជាបន្តបន្ទាប់ និងខិតខំពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសជិតខាង ដើម្បីប្រែក្លាយទៅជាព្រំដែនមួយ ប្រកបដោយកិច្ចសហប្រតិបត្តិការ មានសុខសន្តិភាព និងការអភិវឌ្ឍ ជាពិសេសក្នុងពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានរៀបចំសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ហើយបានដាក់ឆ្លងរដ្ឋសភា និងព្រឹទ្ធសភាពិនិត្យ និងអនុម័តឱ្យបានឆាប់ ដើម្បីជាយន្តការស្របតាមច្បាប់អន្តរជាតិ ធ្វើការបោះបង្គោលព្រំដែន ដើម្បីប្រែក្លាយព្រំដែនមានសន្តិភាព សហប្រតិបត្តិការ និងការអភិវឌ្ឍទុកជាមរតកសម្រាប់កូនចៅជំនាន់ក្រោយៗ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់នូវការខិតខំប្រឹងប្រែងបំពេញតួនាទីភារកិច្ចរបស់ខ្លួនការគោរពវិន័យរបស់កងកម្លាំងបានល្អប្រសើរ ជាពិសេសការលះបង់របស់បងប្អូនដែលត្រូវឃ្លាតឆ្ងាយពីក្រុមគ្រួសារមកបំពេញការងារ និងរស់នៅតំបន់ដាច់ស្រយាល ដើម្បីការពារបូរណភាពទឹកដី។ ក្នុងនោះដែរឯកឧត្តមសូមឱ្យរដ្ឋបាលខេត្តស្ទឹងត្រែង ពិនិត្យលទ្ធភាពពន្លឿនការកសាងហេដ្ឋារចនាសម្ព័ន្ធតាមខ្សែបន្ទាត់ព្រំដែន ដើម្បីសម្រួលដល់ការរស់នៅរបស់ប្រជាជន។ ទន្ទឹមគ្នានោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត បានអំពាវនាវដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ ត្រូវខិតខំថែរក្សាសុខសន្តិភាព ដែលយើងទាំងអស់គ្នារកបានដោយលំបាកនេះ និងបន្តគាំទ្ររាជរដ្ឋាភិបាលបច្ចុប្បន្ន ដើម្បីបន្តដឹកនាំប្រទេសជាតិឆ្ពោះទៅរកភាពរីងមាំរីកចម្រើនបន្តទៅទៀត។ ដោយឡែកចំពោះសំណូមពររបស់វរសេនាតូចការពារព្រំដែនគោកលេខ៧០១ ដែលបានលើកឡើងឯកឧត្តមកិត្តិសង្គហបណ្ឌិតទទួលយក ដើម្បីពិនិត្យលទ្ធភាដោះស្រាយជូនបន្តទៀត។ ក្នុងឱកាសថ្មីខាងមុខនេះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត បានជូនពរដល់អាជ្ញាធរខេត្ត និងកងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៧០១ទាំងអស់ទទួលបានសុខភាពល្អ និងជោគជ័យក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរថែមទៀត។

ក្នុងឱកាសដ៏ថ្លៃថ្លានោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** និងគណៈប្រតិភូបាននាំអំណោយទៅប្រគល់ជូនវរសេនាតូចការពារព្រំដែលលេខ៧០១ រួមមាន៖ ថវិកា ២០លានរៀល កុំព្យូទ័រយួរដៃ១គ្រឿង ម៉ាស៊ីនព្រីនធើ១គ្រឿង ព្រមទាំងជូនដល់កងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនលេខ៧០១ ចំនួន១៦៦នាក់ ដោយក្នុងម្នាក់ៗទទួលបានថវិកា៥ម៉ឺនរៀល អង្ករ១បាវ មី១កេស ទឹកបរិសុទ្ធ១កេស ត្រីខ១យួរ ទឹកត្រី ទឹកស៊ីអ៊ីវ១យួរ សៀង១គីឡូក្រាម និងផ្លែប៉ូវផ្អែម១គីឡូក្រាម៕

(អត្ថបទ៖ លោក នុត សច្ចៈ និងរូបភាព៖ លោក គឹម សិទ្ធី)



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ប្រគល់អំណោយជូនវរសេនាតូចការពារព្រំដែនគោកលេខ៧០១*

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ បានអញ្ជើញប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធមាតា បិតា ញាតកាទាំង៧សន្តាន នៅឃុំកោះសូទិន ខេត្តកំពង់ចាម។



❈នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបសំណេះសំណាលជាមួយអតីតលោកគ្រូ អ្នកគ្រូ លោកគ្រូ អ្នកគ្រូចូលនិវត្តន៍ និងលោកគ្រូ អ្នកគ្រូចំនួន៤០នាក់ នៅវិទ្យាល័យកោះសូទិន ស្ថិតក្នុងឃុំកោះសូទិន ស្រុកកណ្តាលកោះ ខេត្តកំពង់ចាម។



❈នារសៀលថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញនាំយកនូវបច្ច័យ ទេយ្យទាន និងសម្ភារៈបរិក្ខារផ្សេងៗ ទៅថ្វាយសម្តេចព្រះពោធិវ័ង្សកិត្តិបណ្ឌិត **អ៊ំ លឹមហេង** (សង្ឃហត្ថេរោ) សម្តេចព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តចំពុះក្អែក ស្ថិតក្នុងសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។



## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹង ប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នៅថ្ងៃទី១ ខែមេសា ឆ្នាំ ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ ព្រឹទ្ធសភា និងលោកជំទាវ បានអញ្ជើញពិនិត្យវឌ្ឍនភាព នៃការសាងសង់អគារសិក្សាថ្មី ១ខ្នង នៅសាលាបឋមសិក្សាទេពនិម្មិត ស្ថិតក្នុងឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។



❈នាថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ ព្រឹទ្ធសភា និងលោកជំទាវ បានអញ្ជើញនាំយកទេយ្យវត្ថុ គ្រឿងឧបភោគបរិភោគ និងបច្ច័យមួយចំនួនទៅវេរប្រគេនព្រះសង្ឃ នៅវត្តទេពនិម្មិត ហៅវត្តអញ្ចាញ ស្ថិតក្នុងឃុំក្របៅ ស្រុកកំចាយមារ និងវត្តពង្រវង្ស៊ី ហៅវត្តជ្រៃម្រាក់ ស្ថិតក្នុងឃុំគោកគង់កើត ស្រុកកញ្ជៀច ខេត្តព្រៃវែង។



❈នារសៀលថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ឆែព ខន** អនុប្រធានទី២ ព្រឹទ្ធសភា បានអញ្ជើញត្រួតពិនិត្យទីតាំងរៀបចំពិធីកាត់ឫសសីមា និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវព្រះវិហារថ្មី នៅវត្តលុម្ពិនីសាលវ័ននារាម ហៅវត្តអូរសោម ស្ថិតក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់៕



# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញចុះជួបសំណេះសំណាល ជាមួយនឹងអាជ្ញាធរឃុំចំនួន៥ ក្នុងស្រុកពញាក្រែក




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលជាមួយនឹងអាជ្ញាធរឃុំចំនួន៥ ក្នុងស្រុកពញាក្រែក*

នាព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដឹកនាំដោយឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុម បានអញ្ជើញចុះជួបសំណេះ-សំណាលជាមួយនឹងអាជ្ញាធរ និងក្រុមប្រឹក្សាឃុំចំនួន៥ គឺ ឃុំត្រពាំងផ្លុង ឃុំក្រែក ឃុំកណ្តោលជ្រុំ ឃុំពពេល និងឃុំកោងកាង ស្ថិតក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ដើម្បីស្តាប់សំណូមពរ និងគោលការណ៍ចាំបាច់របស់ក្រុមប្រឹក្សា-ឃុំផ្តោតសំខាន់លើការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ និងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា-ឃុំ និងរដ្ឋបាលឃុំ ព្រមទាំងការអនុវត្តគោលនយោបាយ-ភូមិ ឃុំមានសុវត្ថិភាព ដោយមានការអញ្ជើញចូលរួមពីក្រុម-ប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសរុបចំនួន៦៨រូប។

តាមរយៈការធ្វើសេចក្តីរាយការណ៍របស់អាជ្ញាធរ និងក្រុមប្រឹក្សាឃុំទាំង៥រួចមក ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹង-ប្រែងអនុវត្តន៍តួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការបម្រើសេវារដ្ឋ-បាលសាធារណៈ ជូនដល់បងប្អូនប្រជាពលរដ្ឋ ដែលទទួលបាននូវលទ្ធផលល្អប្រសើរគួរជាទីមោទកភាព។ លទ្ធផលទាំងនេះស្តែងឱ្យឃើញថា ព្រះរាជាណាចក្រកម្ពុជាកំពុងទទួលបានសុខសន្តិភាពពេញលេញទាំងថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន។

ទន្ទឹមនឹងលទ្ធផលដែលសម្រេចបាននាពេលកន្លងមក ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានជំរុញ និងលើកទឹកចិត្តឱ្យអាជ្ញាធរឃុំទាំងអស់បន្តយកចិត្តទុកដាក់អនុវត្តន៍តួនាទីរបស់ខ្លួននៅក្នុងមូលដ្ឋានឱ្យកាន់តែប្រសើរថែមទៀត ដោយផ្តោតលើការផ្តល់សេវារដ្ឋបាល ការធ្វើសៀវភៅស្នាក់នៅ





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ជូនដល់អាជ្ញាធរឃុំទាំង៥ ក្នុងស្រុកពញាក្រែក*




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរឃុំទាំង៥ ក្នុងស្រុកពញាក្រែក*

សៀវភៅគ្រួសារ ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មូលនិធិអភិវឌ្ឍន៍ឃុំ និងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសត្រូវធ្វើយ៉ាងណាចូលរួមស្វែងរកដំណោះស្រាយឱ្យបានទាន់ពេលវេលា ពាក់ព័ន្ធទៅនឹងបញ្ហាប្រឈម សេចក្តីត្រូវការ និងសំណូមពររបស់បងប្អូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានរៀងៗខ្លួន។

ឯកឧត្តមបានផ្តាំផ្ញើដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ សូមបន្តយកចិត្តទុកដាក់ប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាលនានា ព្រមទាំងឱ្យមានការប្រុងប្រយ័ត្នឱ្យបានខ្ពស់ចំពោះការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ និងអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់បន្តចូលរួមជាមួយនឹងរាជរដ្ឋាភិបាលក្នុងការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ឱ្យបានគ្រប់ៗគ្នា។ ដោយឡែកចំពោះបញ្ហាប្រឈម និងសំណូមពរនៅសេសសល់ដែលអាជ្ញាធរឃុំពុំអាចដោះស្រាយបាន ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នឹងលើកជាអនុសាសន៍ដល់អាជ្ញាធរមានសមត្ថកិច្ច មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ក៏ដូចជាស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគ្រប់យន្តការនានា ដើម្បីចូលរួមរកវិធីសាស្ត្រដោះស្រាយឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ក្នុងបរិយាកាសដ៏ប្រសើរនេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ក៏បានផ្តល់ជូនដល់អាជ្ញាធរ នៃឃុំទាំង៥ ដែលបានអញ្ជើញចូលរួម ដោយក្នុងម្នាក់ៗទទួលបានឧបករណ៍តេស្តរហ័សជំងឺកូវីដ-១៩ ចំនួន១ប្រអប់តូច។ បន្ទាប់មកនាព្រឹកថ្ងៃដដែលនេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានអញ្ជើញនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន២កេសធំ ស្មើនឹង៥៤ប្រអប់តូច និងជែលលាងដៃ៣០ដប ផ្តល់ជូនដល់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ៕

(អត្ថបទ និងរូបភាព៖ វ៉ាន់ ពិសិដ្ឋ)



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នាំយកអំណោយជូនដល់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិពញាក្រែក ខេត្តត្បូងឃ្មុំ*

# សាស្ត្រាចារ្យ និស្សិត និងសមណនិស្សិត នៃសកលវិទ្យាល័យវេស្ទើន ចំនួន៩៧នាក់ អញ្ជើញទស្សនកិច្ចឈ្វេងយល់អំពីព្រឹទ្ធសភា




*ឯកឧត្តម ម៉ាន់ ឈឿន (កណ្ដាល) អញ្ជើញធ្វើបទបង្ហាញ*

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំពិធីទទួលបដិសណ្ឋារកិច្ចសាស្ត្រាចារ្យ និស្សិត និងសមណនិស្សិត នៃសកលវិទ្យាល័យវេស្ទើន សរុបចំនួន៩៧នាក់ ដែលបានអញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ ដោយមានការធ្វើបទបង្ហាញពីឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ស្ដីពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា លោកស្រី **ឃុន សុវណ្ណនេត្រា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ធ្វើបទបង្ហាញស្ដីពី រចនាសម្ព័ន តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងលោក **សុខ សុជាតិ** ជំនួយការឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ធ្វើបទបង្ហាញស្ដីពីដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ាន់ ឈឿន** បានមានប្រសាសន៍ថា ប្រទេសកម្ពុជាមានសច្ចធម៌ប្រវត្តិសាស្ត្រដូច្នេះ គឺមានសន្តិភាព និងមានការអភិវឌ្ឍ។ ក្នុងនោះសាវតាររបស់ព្រឹទ្ធសភា មានតាំងពីនីតិកាលទី១ ដល់នីតិកាលទី៤ នីតិកាលនីមួយៗរបស់ព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំ។ សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងត្រូវជ្រើសតាំងខ្លះ និងដោយការបោះឆ្នោតអសកល សមាជិកព្រឹទ្ធសភាយ៉ាងច្រើនស្មើ១/២ នៃចំនួនសមាជិករដ្ឋសភា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។

ឯកឧត្តមបានបន្តទៀតថា ព្រឹទ្ធសភានីតិកាលទី៤ មានគណៈកម្មការចំនួន១០ មានតួនាទី ភារកិច្ចជាសេនាធិការឱ្យព្រឹទ្ធសភា ដើម្បីជួយជ្រោមជ្រែងព្រឹទ្ធសភា ក្នុងការតាក់តែង និងប្រតិបត្តិច្បាប់ឱ្យកាន់តែមានភាពល្អប្រសើរឡើង និងចូលរួមចំណែកជំរុញឱ្យការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការនៅកម្ពុជា កាន់តែមានសន្ទុះរីក-



*ទិដ្ឋភាពរួមក្នុងពិធីធ្វើបទបង្ហាញ*

ចម្រើនថែមទៀត ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងការគ្រប់គ្រងសេដ្ឋកិច្ច សង្គម វប្បធម៌ ឱ្យប្រព្រឹត្តទៅដោយសមធម៌ មានតម្លាភាព និងគណនេយ្យភាពយ៉ាងពិតប្រាកដ។

ឯកឧត្តមបានបញ្ជាក់ថា ព្រឹទ្ធសភាមានមុខងារស្នូលចំនួន៣គឺ៖មុខងារនីតិកម្ម មុខងារជាតំណាង និងមុខងារត្រួតពិនិត្យតាមដានការអនុវត្តច្បាប់។ មុខងារទាំង៣នេះមានសារៈសំខាន់ណាស់ក្នុងការជួយជំរុញឱ្យសេចក្ដីព្រាងច្បាប់ដែលរាជរដ្ឋាភិបាល បាននឹងកំពុងតាក់តែងឡើងកាន់តែមានប្រសិទ្ធភាពជាងមុនថែមទៀត ដើម្បីបម្រើផលប្រយោជន៍ជូនសង្គមជាតិ និងប្រជាពលរដ្ឋទូទាំងប្រទេសឱ្យកាន់តែមានតម្លាភាព និងសុក្រឹតយុត្តិធម៌។

បន្ទាប់ពីស្ដាប់បទបង្ហាញរួច សាស្ត្រាចារ្យ និស្សិត និងសមណនិស្សិត បានអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា បណ្ណាល័យព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានានៅក្នុងបរិវេណព្រឹទ្ធសភា។

សូមបញ្ជាក់ថា វិមានព្រឹទ្ធសភា ជាអតីតវិមានរដ្ឋចំការមន ដែលត្រូវបានផ្ដួចផ្ដើមគំនិតកសាងឡើងក្នុងទសវត្សរ៍ទី៥០ ដោយព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ។ វិមានរដ្ឋចំការមន គឺជាទីកន្លែងសម្រាប់ទទួលបដិសណ្ឋារកិច្ចប្រមុខរដ្ឋ នៃប្រទេសនានា ជាកន្លែងធ្វើការងារ និងជាព្រះរាជដំណាក់របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះរាជដំណាក់របស់ព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងព្រះរាជដំណាក់របស់ព្រះរាជបុត្រីព្រះរៀម **នរោត្តម បុប្ផាទេវី**។ ក្រៅពីនេះ នៅក្នុងវិមានរដ្ឋចំការមន ក៏មានសាលបដិសណ្ឋារកិច្ច សាលរៀបចំពិធីជប់លៀង អគារការិយាល័យ កន្លែងស្នាក់នៅរបស់ភ្ញៀវ និងរោងភាពយន្តផងដែរ។ បច្ចុប្បន្នវិមានរដ្ឋចំការមន គឺជាកន្លែងធ្វើការរបស់ស្ថាប័នកំពូលៗចំនួន៣ស្ថាប័ន គឺ៖ ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ និងឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដែលមានអាសយដ្ឋាននៅតាមបណ្ដោយមហាវិថីព្រះនរោត្តម ជាប់វិមាន៧មករា (គណបក្សប្រជាជនកម្ពុជា)៕

(អត្ថបទ និងរូបភាព៖ លោក អ៊ុក ប៉ូលីន)









*លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទស្សនកិច្ចនៅវិមានព្រឹទ្ធសភា*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❋ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំ៖



-គណៈកម្មការទី១ព្រឹទ្ធសភា ដើម្បីពិនិត្យលើរបាយការណ៍ប្រចាំត្រីមាសទី១ឆ្នាំ២០២៣ របស់គណៈកម្មការទី១ព្រឹទ្ធសភា ការរាយការណ៍អំពីថវិកា និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។



-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដើម្បីពិនិត្យឆ្លងរបាយការណ៍ត្រីមាសទី១របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ការរាយការណ៍អំពីថវិកា និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។

-ជាមួយនឹងម្ចាស់បណ្ដឹង លោក **នាក់ ស៊ូហ្វីយាន** ជាអតីតទីប្រឹក្សារបស់អភិបាលក្រុងព្រះសីហនុ នៃអាណត្តិរដ្ឋសភា នីតិកាលទី១ និងសព្វថ្ងៃជាទីប្រឹក្សាកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលបានដាក់ពាក្យបណ្ដឹងមកសម្ដេចប្រធានព្រឹទ្ធសភា ជួយអន្តរាគមន៍ករណីដាក់ឱ្យរូបគាត់ចូលនិវត្តន៍ដែលខុសពីលក្ខន្តិកៈដែលបានចែងអំពីការចូលនិវត្តន៍របស់មន្ត្រីរាជការក្នុងអាយុ៦០ឆ្នាំ និងសុំឱ្យផ្ដល់តួនាទីជានាយក នៃនាយកដ្ឋានគ្រឿងចក្រឱ្យរូបគាត់ដូចដើមវិញ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។



❋នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ សាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ជេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា ដើម្បី៖

១-ត្រៀមលក្ខណៈទទួល និងពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី សារពើពន្ធ និងសេចក្ដីព្រាងច្បាប់ស្ដីពី លទ្ធកម្មសាធារណៈ ស្ថិតក្នុងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ សេចក្ដីព្រាងច្បាប់ស្ដីពី សារពើពន្ធ និងសេចក្ដីព្រាងច្បាប់ស្ដីពី លទ្ធកម្មសាធារណៈ

២-ត្រៀមលក្ខណៈចូលរួមពិធីកាត់ឫសសីមា សម្ពោធដាក់ឱ្យប្រើប្រាស់ព្រះវិហារថ្មីរបស់វត្តលុម្ពិនីសាលវ័ននារាម (ហៅវត្តអូរសោម) នៅស្រុកវាលវែង ខេត្តពោធិ៍សាត់

៣-បញ្ហាផ្សេងៗ។

❋ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំ៖



-ជាមួយនឹងគណៈកម្មការទី៥ និងគណៈកម្មការទី៦ព្រឹទ្ធ-សភា ដើម្បីពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពី ការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅសាលប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា នារសៀលថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣។



-អន្តរគណៈកម្មការព្រឹទ្ធសភាប្រជុំជាមួយនឹងតំណាងរាជរដ្ឋាភិបាលដឹកនាំដោយ ឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋ-មន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន និងជាប្រធានគណៈកម្មការចម្រុះកិច្ចការព្រំដែន ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាង-ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជា-ធិបតេយ្យប្រជាមានិតឡាវ នៅសាលសិក្ខាសាលាខាងជើងព្រឹទ្ធសភា នាព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣។

-ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បីពិនិត្យ និងពិភាក្សាត្រៀមយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាង



ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យ-ប្រជាមានិតឡាវ នៅសាលប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។



❈នាព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា លោកជំទាវកិត្តិនីតិកោសល-បណ្ឌិត **ទី ម្វ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា ដើម្បី៖

១-ពិនិត្យរបាយការណ៍សកម្មភាពការងាររបស់គណៈ-កម្មការប្រចាំខែមីនា និងលើកទិសដៅការងារអនុ-វត្តបន្ត

២-ពិនិត្យរបាយការណ៍ស្តីពី លទ្ធផល នៃកិច្ចប្រជុំពិភាក្សាការងារជាមួយនឹងក្រសួងព័ត៌មាន កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ កន្លងទៅ

៣-ការបូកសរុបចំណូល ចំណាយថវិការបស់គណៈ-កម្មការប្រចាំខែមីនា និងប្រចាំត្រីមាសទី១

៤-ពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជា-

ធិបតេយ្យប្រជាមានិតឡាវ

៥-បញ្ហាផ្សេងៗ។

❋ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំ៖



-ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ដើម្បីពិនិត្យ និងពិភាក្សាត្រៀមយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣។



-ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា នាថ្ងៃទី២០ ខែមេសា ឆ្នាំ ២០២៣ ដើម្បីពិនិត្យពិភាក្សា និងត្រៀមយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៣គឺ៖

១-សេចក្តីព្រាងច្បាប់ស្តីពី សារពើពន្ធ

២-សេចក្តីព្រាងច្បាប់ស្តីពី លទ្ធកម្មសាធារណៈ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្មតាមព្រំដែនរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។



❋នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ខឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអនុញ្ញាតឱ្យក្រុមការងាររបស់សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដឹកនាំដោយឯកឧត្តមបណ្ឌិត **ហេង សុផាឌី** សកលវិទ្យាធិការ នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ចូលជួប និងពិភាក្សាការងារស្តីពី ការរៀបចំបោះពុម្ពសៀវភៅ ដែលជាស្នាដៃស្រាវជ្រាវរបស់សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។



❋នាព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា ដើម្បី៖

១-បូកសរុបលទ្ធផលការងាររបស់គណៈកម្មការប្រចាំត្រីមាសទី១ ឆ្នាំ២០២៣

២-ការទូទាត់ចំណូល ចំណាយថវិការបស់គណៈកម្មការប្រចាំត្រីមាសទី១ ឆ្នាំ២០២៣

៣-បញ្ហាផ្សេងៗ។

❈ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំ៖



-ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មតាមព្រំដែន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសាលប្រជុំពិសេសព្រឹទ្ធសភា នារសៀលថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣។

❈នារសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យឆ្លងរបាយការណ៍ស្តីពី សកម្មភាពលទ្ធផលការងារ របាយការណ៍ថវិការបស់គណៈកម្មការប្រចាំខែមេសា និងលើកទិសដៅការងារបន្ត នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។

❈នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំសំណេះសំណាល សួរសុខទុក្ខជាមួយនឹងថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ទូទាំងខេត្តតាកែវ ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ឃឹន ឈិន** ប្រធានក្រុមការងារចុះជួយខេត្តតាកែវ តាមប្រព័ន្ធវីដេអូ Zoom នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា៕

## ការទទួលពាក្យបណ្តឹង

❈នៅខែមេសា ឆ្នាំ២០២៣ គណៈកម្មការទី១ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន៥ករណី បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៣ករណី (ពាក្យបណ្តឹងសល់ពីខែមីនាចំនួន១ករណី) ធ្វើកំណត់បង្ហាញពាក្យបណ្តឹងបានចំនួន៣ករណី កំពុងពិនិត្យសិក្សាចំនួន៤ករណី ឆ្លើយតបទៅម្ចាស់បណ្តឹង (ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង) ចំនួន៣ករណី និងទទួលឯកសារជូនជ្រាបដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបបានចំនួន១ករណី៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

❈ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២១ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និងឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារសើរើលក្ខន្តិកៈ APF និងកិច្ចប្រជុំគណៈកម្មការនយោបាយ APF នៅទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង៕



# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❈នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធវីរបុរសលោកអាចារ្យ **ហ៊ុល ដួង** ដែលជាសិស្សជំនិតលោកអាចារ្យ **ហែម ចៀវ** ដែលបានតស៊ូទាមទារកុំឱ្យបារាំងលុបបំបាត់អក្សរសាស្ត្រខ្មែរ និងទាមទារឯករាជ្យពីអាណានិគមបារាំង ព្រមទាំងបង្សុកូលជូនដល់លោកអ្នកដ៏មានគុណទាំងអស់របស់ប្រជាពលរដ្ឋ នៅសង្កាត់រកាកណ្តាល និងប្រគេនទេយ្យវត្ថុ ថវិកាដល់ព្រះសង្ឃ ជូនថវិកាដល់លោកតាអាចារ្យ លោកយាយ លោកតា ចៅសង្កាត់ ប្រធានប៉ុស្តិ៍ ប្រធានភូមិ១ ភូមិ២ ប្រជាការពារភូមិ១ ភូមិ២ និងទស្សនារបាំសម្តែងដោយក្រុមសិល្បៈ យុវជន យុវនារី (ស.ស.យ.ក.ខេត្តក្រចេះ) និងឧបត្ថម្ភថវិកាមួយចំនួន។

❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះសួរសុខទុក្ខឧបាសិកា **គ្រុយ ឆេង** ត្រូវជាម្តាយមីងបង្កើតដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ស្ថិតនៅឃុំស្រង៉ែ ស្រុកព្រៃឈរ ខេត្តកំពង់ចាម នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលក្រុមប្រឹក្សាសង្កាត់ នាយប៉ុស្តិ៍នគរបាល ស្មៀន និងមន្ត្រី ដើម្បីស្តាប់របាយការណ៍ស្ថានភាពទូទៅរបស់សង្កាត់ ការអភិវឌ្ឍមូលដ្ឋានសង្កាត់ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ការដំណើរការសេវាជូនប្រជាពលរដ្ឋ និងការតាមដានការងារបន្ទាប់ពីការរៀបចំវេទិការបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ព្រមទាំងនាំយកនូវអង្ករចំនួន១៥បាវ ឧបករណ៍ធ្វើតេស្តរហ័សកូវីដ-១៩ ចំនួន២៧ប្រអប់ និងជែលលាងដៃមួយប្រអប់ធំ ប្រគល់ជូនរដ្ឋបាលសង្កាត់បឹងធំ ដើម្បីទុកចែកជូនប្រជាពលរដ្ឋក្រីក្រក្នុងមូលដ្ឋាន និងសម្រាប់បំពេញការងារមនុស្សធម៌ផ្សេងៗ នៅសាលាសង្កាត់បឹងធំ រាជធានីភ្នំពេញ នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ និងណែនាំពួកគាត់អំពីការងារថែទាំបច្ចេកទេសដាំដុះវិស័យកសិកម្ម ព្រមទាំងនាំយកអាហារកញ្ចប់ និងថវិកាមួយចំនួន នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារចុះពិនិត្យ និងជំរុញការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវមួយខ្សែប្រវែង១៧គីឡូម៉ែត្រ នៅភូមិមនោរម្យ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករកំពុងប្រមូលផលផ្លែទុរេន ព្រមទាំងជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ និងនាំយកអំណោយមួយចំនួនចែកជូនពួកគាត់ នៅភូមិមនោរម្យ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់វិទ្យាល័យ ហ៊ុន សែន កែវផុស ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅភូមិឫទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងនាំយកអំណោយ និងថវិកាមួយចំនួន នៅឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី២ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ

ព្រមទាំងបានដឹកនាំពួកគាត់ពិនិត្យមើលសមិទ្ធផលនានា នៅតំបន់អភិវឌ្ឍន៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងនាំយកអំណោយ និងថវិកាមួយចំនួន នៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលសួនបន្លែ និងចម្ការឈើហូបផ្លែ ប្រព័ន្ធប្រឡាយទឹក ទំនប់ទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។

-ដឹកនាំលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋរួមគ្នាដាំដើមឈើផ្ទង់នៅបរិវេណបឋមសិក្សា និងវិទ្យាល័យឫទ្ធីកែវផុស ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅភូមិមនោរម្យ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងចុះពិនិត្យមើលដើមឈើអភិរក្សថែរក្សាការពាររយៈពេល៣០ឆ្នាំ នៅភ្នំតាង៉ែត ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣។

-ចុះត្រួតពិនិត្យវឌ្ឍនភាព នៃការងារស្ថាបនាផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ៤ ត្រង់ចំណុចគីឡូម៉ែត្រលេខ១៥៨+២៩១ ឆ្លងកាត់ចម្ការដូងប្រេងប្រវែង១៥គីឡូម៉ែត្រ ឆ្ពោះទៅខ្នងភ្នំបូកគោ ប្រវែង៦១គីឡូម៉ែត្រ នៅខ្នងភ្នំបូកគោ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋកំពុងនេសាទត្រី ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនដល់ពួកគាត់ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ និងឧបត្ថម្ភថវិកាមួយចំនួន ព្រមទាំងជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋអញ្ជើញមកសម្រាកកំសាន្ត និងទស្សនាសួនសត្វនៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ម៉ុង ឫទ្ធីសែនជ័យ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣ នៅភ្នំសែនជ័យ ស្រុកសំរោង-ទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារបច្ចេកទេសចុះពិនិត្យដំណាំកសិកម្ម កសិ-ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធផ្លូវ លូ ស្ពាន និងទំនប់-ទឹក នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមអ្នកជំនាញបច្ចេកទេសកសិកម្ម រៀបចំសម្អាតដីសម្រាប់ដាំដូងក្រអូបចំនួន៦២ហិកតា ស្មើនិង៧៣.៣៦០ ដើម នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣។



❋នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលនានាក្នុងវត្តបុសមន ក្រោមអធិបតីភាពឯកឧត្តម **ម៉ែន វិបុល** អភិបាល នៃគណៈអភិបាលខេត្តស្វាយរៀង នៅឃុំបុសមន ស្រុករំដួល ខេត្តស្វាយរៀង។

❋ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះពិនិត្យការកសាងអគារសិក្សាថ្មីមួយខ្នង ៥បន្ទប់ ជូនបឋមសិក្សាហ៊ុនសែនបុសមនលើ នៅស្រុករំដួល ខេត្តស្វាយរៀង នារសៀលថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់



នៃស្រុកពាមរក៍ នៅសាលាខេត្តព្រៃវែង នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រធានមណ្ឌលសុខភាពទាំង១១ នៃស្រុកព្រះស្ដេច នៅសាលាខេត្តព្រៃវែង នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។

❈លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុក ឃុំ និងលោកតា លោកយាយមកពីភូមិទាំង១៥ និងលោក លោកស្រីមន្ត្រី ឃុំភូមិ ព្រមទាំងឧបត្ថម្ភលោកតា លោកយាយ និងប្រគេនព្រះសង្ឃជាថវិកា ឬបច្ច័យ សម្ភាររួមមាន៖ ក្រមា១ ថ្នាំKAL-CEEOrange១ទីប ប្រេងកូឡា១ប្រអប់ ទឹកត្រចៀកកាំ១ដប ទឹកបរិសុទ្ធ១ដប និងថវិកាមួយចំនួនឧបត្ថម្ភមន្ត្រីភូមិ ឃុំ ថវិកា និងទឹកត្រចៀកកាំមួយចំនួន ក្នុងឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាស្រុកពញាឮ ដើម្បី



យកសៀវភៅមួយចំនួនដាក់តាមបណ្ណាល័យនៅវិទ្យាល័យនានាក្នុងស្រុកពញាឮ ព្រមទាំងជួបសំណេះសំណាលពិភាក្សាការងារមួយចំនួនជាមួយនឹងលោក **នុត ប៉ាត** ទីប្រឹក្សាក្រសួងធនធានទឹក និងឧតុនិយម នៅខេត្តកណ្ដាល នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាភូមិ ឃុំ សង្កាត់ ខណ្ឌកំបូល និងខណ្ឌពោធិ៍សែនជ័យ ដើម្បីឈ្វេងយល់ពីការផ្ដល់សេវាសាធារណៈ ការអនុវត្តគោលនយោបាយភូមិ សង្កាត់ មានសុវត្ថិភាព និងការងារអភិវឌ្ឍមូលដ្ឋាន ព្រមទាំងបានឧបត្ថម្ភឧបករណ៍តេស្តរហ័ស និងថវិកាមួយចំនួន ស្ថិតក្នុងរាជធានីភ្នំពេញ នាថ្ងៃទី៣០ ខែមីនា ថ្ងៃទី៥ ថ្ងៃទី១២ និងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣។



-នាំយកនូវចង្ហាន់ ទេយ្យវត្ថុជាគ្រឿងឧបភោគ បរិភោគ និងបច្ច័យទៅប្រគេនព្រះសង្ឃ ដើម្បីរៀបចំពិធីបង្សុកូលតាមទំនៀមទម្លាប់ខ្មែរ និងតាមគន្លងព្រះពុទ្ធសាសនា ព្រម-

ទាំងឧទ្ទិសកុសលផលបុណ្យជូនដល់ដួងវិញ្ញាណក្ខន្ធមាតា បិតា ញាតកាទាំងប្រាំពីរសន្តាន ឥស្សរជន និងយុទ្ធជន ដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងឧបត្ថម្ភថវិកាជូនប្រជាការពារ យាយជី តាជី និងបច្ច័យមួយចំនួន សម្រាប់កសាងសមិទ្ធផលក្នុងវត្ត នៅវត្តអង្គរុន ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ នាថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០២៣។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំ និងនាយប៉ុស្តិ៍នគរបាលឃុំអំពិលក្រៅ នៅសាលាឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នារសៀលថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលនានា ក្នុងវត្តសិរីមង្គល (ហៅវត្តអំពិលក្រៅ) នៅឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខតាមខ្នងផ្ទះប្រជាពលរដ្ឋរស់នៅឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំខេត្តពោធិ៍សាត់ និងមន្ត្រីពាក់ព័ន្ធ ដើម្បីត្រៀមរៀបចំពិធីកាត់បួសសីមា និងសម្ពោធដាក់ឱ្យប្រើប្រាស់ព្រះវិហារថ្មីរបស់វត្តលុម្ពិនីសាលវ័ននារាម (ហៅវត្តអូរសោម) នៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ នារសៀលថ្ងៃទី១១ និងទី១៩ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យសម្ពោធឆ្លងមហាចេតិយ ដែលជាស្តូបអនុស្សាវរីយ៍ ដើម្បីតម្កល់អដ្ឋិធាតុយុទ្ធជនកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ៤៩រូប ព្រមទាំងនាំយកបច្ច័យរបស់គណៈកម្មការទី១០ព្រឹទ្ធសភា ចូលបុណ្យនូវថវិកាមួយចំនួន នៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងពិធីអបអរសាទរសន្និបាតសមាគមមនុស្សចាស់ ឃុំត្រពាំងវែង ឆ្នាំ២០២២ និងលើកទិសដៅឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនសមាជិក នៃអង្គពិធី និងចូលរួមរំលែកទុក្ខជាមួយនឹងប្រជាពលរដ្ឋដែលមានសមាជិកគ្រួសារទើបទទួលមរណភាពចំនួន៨គ្រួសារ និងចូលបច្ច័យបុណ្យនូវថវិកាមួយចំនួន នៅឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នាព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងពិធីសំណេះសំណាលក្រុមការងារចុះជួយខេត្តកណ្តាល ក្រោមអធិបតីភាពឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្រុងតាខ្មៅ ខេត្តកណ្តាល នាព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣។



❈នាថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភា ឯកឧត្តម **លី សាវី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃបេសកកម្មមនុស្សធម៌ (AMH) នៃប្រទេសបារាំង នៅកម្ពុជា របស់ឯកឧត្តម

កិត្តិសង្គហបណ្ឌិត **តេព ខន** អនុប្រធានទី២ព្រឹទ្ធសភា ចុះពិនិត្យ និងព្យាបាលជំងឺទូទៅឥតយកកម្រៃជូនប្រជាពលរដ្ឋក្រីក្រ នៅក្នុងបរិវេណវិទ្យាល័យ ហ៊ុន សែន ចំការដូង ព្រមទាំងបានផ្ដល់ជូនឧបករណ៍ធ្វើតេស្តកូវីដ-១៩ ចំនួន៣កេសធំ ជូនដល់ខេត្តកែប ខេត្តកំពត និងខេត្តតាកែវ និងចែកជូននូវក្រមាដល់ក្រុមគ្រូពេទ្យចំនួន១៦នាក់ ដើម្បីទុកជាអនុស្សាវរីយ៍ នៅស្រុកដំណាក់ចង្អើរ ខេត្តកែប។

❋ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខ និងឈ្វេងយល់អំពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព៧ចំណុច ព្រមទាំងបានឧបត្ថម្ភឯកសណ្ឋានថ្មីដល់ប្រជាការពារភូមិសរុបចំនួន១១៥នាក់ ក្នុងឃុំតាភេម នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីកាត់ឫសសីមាព្រះវិហារ និងឆ្លងសមិទ្ធផលនានាក្នុងវត្តអង្គជុំមានលក្ខណ៍ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅភូមិបាខុងខាងលិច ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។



-ជួបសណេះសំណាល និងសួរសុខទុក្ខលោកតា លោកយាយ ចំនួន២០០នាក់ ដែលមកសម្មាទានសីល ព្រមទាំងចែកអំណោយជូនលោកតា លោកយាយ នូវសម្លៀកបំពាក់ថ្មី ដើម្បីចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរខាងមុខនេះ នៅសាលាបុណ្យ ស្ថិតក្នុងឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣។

-ចុះសួរសុខទុក្ខប្រជាពលរដ្ឋដែលរងគ្រោះដោយសារខ្យល់ព្យុះកន្ត្រាក់បាក់រលំផ្ទះសម្បែង កាលពីយប់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣ នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងលើកទិសដៅការងារបន្តរបស់ឃុំកោះសំពៅ នៅសាលាស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីបុណ្យឆ្លងសមិទ្ធផលនានាក្នុងវត្តព្រៃល្វាយ ហៅ “វត្តសិរីមង្គល” ព្រមទាំងនាំយកបច្ច័យមួយចំនួនចូលរួមចាប់មគ្គផលក្នុងពិធីបុណ្យ នៅឃុំទឹកថ្លាម ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង នាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៣។



❋នាព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី និងសម្ពោធឆ្លងសមិទ្ធផលនានា ក្នុងវត្តទឹកជុំមានជ័យ (វត្តកោះចារ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ថិតនៅឃុំកកោះ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។

❋ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធី៖

-បួងសួងសុំសេចក្ដីសុខ នាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ នៅប្រាសាទបាណន់ ស្រុកបាណន់ ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣។

-សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារបម្រើការងារ១ខ្នង កម្ពស់២ជាន់ មាន១៤បន្ទប់ ព្រមទាំងសំណេះសំណាលជាមួយនឹងនិវត្តន៍ជនចំនួន៥០៤នាក់ និងមន្ត្រីនគរបាល នៃ

ស្នងការដ្ឋាននគរបាលខេត្តចំនួន៨៨១នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង នៅខេត្តបាត់ដំបង នាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣។

❈នារសៀលថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និង ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបើកព្រឹត្តិការណ៍សង្ក្រាន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ នៅខេត្តបាត់ដំបង។



❈នាថ្ងៃទី២ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ឈិត គឹមយ៉ាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាចូលរួមពិធីសំណេះសំណាល សួរសុខទុក្ខ និងនាំយកគ្រឿងឧបភោគ បរិភោគដែលជាអំណោយរបស់អង្គការ LIFE ផ្តល់ជូនដល់បងប្អូនខ្មែរសាសនិកឥស្លាម នៅទូទាំងឃុំព្រែកតានង់ចំនួន៧៩៥គ្រួសារ នៃស្រុកកោះសូទិន ខេត្តកំពង់ចាម។

❈នាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញរៀបចំពិធីបង្សុកូលតាមទំនៀមទម្លាប់ខ្មែរ និងតាមគន្លងព្រះពុទ្ធសាសនា ដើម្បីសុំសេចក្តីសុខ សេចក្តីចម្រើន សិរីសួស្តី ព្រមទាំងឧទ្ទិសកុសលផលបុណ្យជូនដល់ដួងវិញ្ញាណក្ខន្ធមាតា បិតា ញាតកាទាំងប្រាំពីរសន្តាន ដើម្បីចូលរួមអមអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ និងបាននាំយកគ្រឿងបរិក្ខារ បច្ច័យមួយចំនួនសម្រាប់ប្រគេនព្រះសង្ឃគង់ចាំព្រះវស្សានៅវត្តព្រែកស្វាយ ភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរៈភូមិន្ទ ខេត្តកោះកុង។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួម៖



-ក្នុងពិធីសំណេះសំណាល និងផ្សព្វផ្សាយខ្លឹមសារសង្ឃប្រកាសអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣០ និងសេចក្តីសម្រេចចិត្តសង្ឃសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំ២០២២ ប្រគេនជូនដល់គណៈកម្មការអាចារ្យវត្តសីលវ័ន្ត សីលវតី និងសិស្ស និស្សិតស្នាក់នៅទាំង១៣វត្ត ក្រោមអធិបតីភាពព្រះឧបាលិវង្ស **វ៉ង់ គឹមសន** ព្រះគ្រូអនុគណខណ្ឌពោធិ៍សែនជ័យ នៅវត្តជម្ពូវ័ន ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣។



-ពិធីសូត្រមន្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ដើម្បីប្រោះព្រំសុំនូវសេចក្តីសុខ និងសិរីសួស្តីជូនចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ នៅរាជធានីភ្នំពេញ នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣។



-ពិធីសូត្រមន្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ដើម្បីបង្សុកូលឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធបុព្វបុរស និងប្រជាជនដែលបាន

ស្លាប់ក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត នៅមជ្ឈមណ្ឌល ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក រាជធានីភ្នំពេញ នាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក និងកងកម្លាំងនគរបាល ប្រជាការពារ ព្រមទាំងឧបត្ថម្ភអង្ករ កន្សែងពោះគោ និងឧបករណ៍តេស្តរហ័ស សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ នាថ្ងៃទី២៩ ខែមីនា និងថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមពិធីសូត្រមន្តលើករាសី ជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ នគរបាលប៉ុស្តិ៍ មន្ត្រីសាលាសង្កាត់ ប្រធានភូមិទាំង១៣ ក្រុមការងារ ក្នុងឱកាសសង្រ្កាន្តឆ្នាំថ្មីនាពេលខាងមុខ នៅខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមពិធីសូត្រមន្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ដើម្បីប្រោះព្រំសុំនូវសេចក្តីសុខ និងសិរីសួស្តីជូនចំពោះថ្នាក់ដឹកនាំមន្ត្រីរាជការ សាលារាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **បេ ឆាយអ៊ុំថ** នៅវត្តទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នាថ្ងៃទី



១៧ ខែមេសា ឆ្នាំ២០២៣។



-ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ម៉ែន សាអ៊ុន** ត្រូវជាម្តាយបង្កើតរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថិតនៅបុរីពិភពថ្មី ក្រុងតាខ្មៅ ខេត្តកណ្តាល នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣។



❈នាព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងនាំយកអំណោយជាសម្ភារថវិកាចែកជូនដល់ក្រុមប្រឹក្សាឃុំ កងកម្លាំងនគរបាល និងប្រជាពលរដ្ឋ ព្រមទាំងនាំយកទេយ្យវត្ថុ និងបច្ច័យប្រគេនព្រះចៅអធិការវត្តដំណាក់អំពិល នៅឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩

ព្រឹទ្ធសភាបានអញ្ជើញៈ

-ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋ ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២៦ និងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅអនុវត្តន៍បន្តឆ្នាំ២០២៣ របស់ខេត្តស្វាយរៀង នៅសាលប្រជុំខេត្តស្វាយរៀង នាព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលនិស្សិតមហាវិទ្យាល័យកសិកម្ម នៃសាកលវិទ្យាល័យស្វាយរៀង នៅខេត្តស្វាយរៀង នាថ្ងៃទី៧ និងថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញៈ

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំទាំង១៣ឃុំ នៃស្រុកភ្នំស្រួច ដើម្បីឈ្វេងយល់អំពីការធ្វើ និងផ្ដល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកអំណោយចែកជូនដល់សមាជិកនៃអង្គពិធី ដោយក្នុងម្នាក់ៗទទួលបានៈ ក្រមា១ និងឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន១ប្រអប់ នៅសាលប្រជុំសាលាស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាសង្កាត់ទាំង៥សង្កាត់ នៃក្រុងច្បារមន ដើម្បីឈ្វេងយល់អំពីការធ្វើ និងផ្ដល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកអំណោយមកចែកជូនដល់សមាជិកនៃអង្គពិធី ដោយក្នុងម្នាក់ៗទទួលបានៈ ក្រមា១ និងឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន១ប្រអប់ និងក្រុមប្រឹក្សាក្រុងច្បារមន ដោយក្នុងម្នាក់ៗទទួលបានថវិកាមួយចំនួន និងឧបត្ថម្ភថវិកាមួយចំនួនទៀត ដើម្បីចូលរួមចំណែកក្នុងការកសាងផ្លូវក្នុងក្រុងច្បារមន នៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំទាំង១៣ឃុំ នៃស្រុកគងពិសី ដើម្បីឈ្វេងយល់អំពីការធ្វើ និងផ្ដល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកអំណោយចែកជូនដល់សមាជិកនៃអង្គពិធី ដោយក្នុងម្នាក់ៗទទួលបានៈ ក្រមា១ និងឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន១ប្រអប់ នៅសាលប្រជុំសាលាស្រុកគងពិសី ខេត្តកំពង់ស្ពឺ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំទាំង៧ឃុំ នៃស្រុកថ្ពង ដើម្បីឈ្វេងយល់អំពីការធ្វើ និងផ្ដល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកអំណោយចែកជូនដល់សមាជិកនៃអង្គពិធី ដោយក្នុងម្នាក់ៗទទួលបានៈ ក្រមា១ និងឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន១ប្រអប់ នៅសាលប្រជុំសាលាស្រុកថ្ពង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតគ្រឿងបង្គុំរថយន្តរបស់ក្រុមហ៊ុនយូរ៉ា ហានេស(ខេមបូឌា) YURA Harness (Cambodia) Co,Ltd ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានគណៈកម្មការទី៧រដ្ឋសភា ស្ថិតនៅភូមិទួលធ្នង់ សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣។

❈នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីចម្រើនព្រះបរិត្ត អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ក្រោមអធិបតីភាពលោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការទី៩ រដ្ឋសភា នៅសាលាស្រុកកោះអណ្តែត ខេត្តតាកែវ។



❈នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ លោកជំទាវ **គង សៅវ៉ែន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្ដម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្ដម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលប្រជាពលរដ្ឋ និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រទេសបារាំងរបស់ឯកឧត្ដមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា ដែលបានមកពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាជនក្នុងស្រុកដំណាក់ចង្អើរ ខេត្តកែប។

❈លោកជំទាវ **គង សៅវ៉ែន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញៈ

-ចូលរួមពិធីប្រគល់សញ្ញាបត្រដល់និស្សិតសកលវិទ្យាល័យអង្គរខេមរា ក្រោមអធិបតីភាពឯកឧត្ដមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅសាលសន្និសីទបូកគោ ខេត្តកំពត នាថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមពិធីបុណ្យបញ្ចុះខណ្ឌសីមាវត្តអង្គ្រង់រាជា ក្រោមអធិបតីភាពឯកឧត្ដមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត នាព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមពិធីបុណ្យបញ្ចុះខណ្ឌកាត់ឫសសីមា ក្រោមអធិបតីភាពឯកឧត្ដមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅវត្តកោះផ្ដៅ ភូមិកោះផ្ដៅ ឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត នាព្រឹកថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមពិធីបុណ្យឆ្លងសាលាភគ្គ និងឆ្លងសមិទ្ធផលនានា ក្រោមអធិបតីភាពឯកឧត្ដមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅវត្តគិរីវ័ន ភូមិត្របៀត ឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត នាព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្ដម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្ដម **ឈឿយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជាកិត្តិយសក្នុងពិធីៈ



-បើកព្រឹត្តិការណ៍ “ចូលឆ្នាំបន្ទាយឆ្មារ ក្រោមប្រធានបទជួបជុំគ្រួសារ ចូលឆ្នាំបន្ទាយឆ្មារ ក្រោមម្លប់សន្តិភាព” ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ក្រោមអធិបតីភាពឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** នៅខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣។



-សំណេះសំណាល សួរសុខទុក្ខកងកម្លាំងប្រដាប់អាវុធឈរជើងក្នុងខេត្តបន្ទាយមានជ័យ ចំនួន៧.០១៥នាក់ ក្រោមអធិបតីភាពឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣។

-សំណេះសំណាលបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ រដ្ឋសភា សម្រាប់មណ្ឌលខេត្តបន្ទាយមានជ័យ ទាំង១២រូប (៦រូបបេក្ខជនពេញសិទ្ធិ និង៦រូបបេក្ខជនបម្រុង) ក្រោមអធិបតីភាព

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឆាយ ចន្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖




-ជួបសំណេះសំណាល និងនាំយកអំណោយរបស់សមាគម SMG សម្រាប់ចែកជូនប្រជាពលរដ្ឋនៅភូមិព្រែកប្រាសង្កាត់ព្រែកតាពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនខ្មែរសាសនិកឥស្លាម ព្រមទាំងនាំយកអំណោយរបស់សមាគម SMG រួមមាន៖ មី១កេះ ទឹកដោះគោ២កំប៉ុង ប្រេងឆា១ដប ស្ករ-ស១គីឡូ ប្រេងឆា១ដប ទឹកត្រី១ដប និងទឹកស៊ីអ៊ីវ១ដប សម្រាប់ ស្រាយបួសខែរ៉ាម៉ាឌន នៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីចែកអំណោយអាហារសម្រាប់ស្រាយបួសក្នុងខែរ៉ាម៉ាឌនជូនប្រជាពលរដ្ឋខ្មែរឥស្លាមចំនួន៣០០គ្រួសារ ជាអំណោយរបស់សប្បុរសជនរបស់ប្រទេសគុយវ៉ែតតាមរយៈសមាគមប្រភពល្អកម្ពុជា ដោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ១០គីឡូក្រាម មីយើង១០កញ្ចប់ ស្ករ-ស២គីឡូក្រាម ទឹកត្រចៀកកាំ១០កំប៉ុង ទឹកដោះគោ២កំប៉ុង និងបន្តចុះត្រួតពិនិត្យទីផ្នូរដែលកំពុងធ្វើរបងនៅជិតវិហារកំពង់ត្រឡាចក្រោម និងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិអង្គជា ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយសម្រាប់ស្រាយបួសរបស់សប្បុរសជនប្រទេសគុយវ៉ែត តាមរយៈសមាគមប្រភពល្អកម្ពុជា ដោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករចំនួន២៥គីឡូក្រាម ស្ករ-ស២គីឡូក្រាម អំបិល១គីឡូក្រាម ទឹកដោះគោ២កំប៉ុង និងប្រេងឆា១ដប ចែកជូនបងប្អូនខ្មែរសាសនិកឥស្លាមចំនួន១២០គ្រួសារ នៅភូមិសយ ឃុំបើស១ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយសម្រាប់ស្រាយបួសចែកជូនបងប្អូនសាសនិកឥស្លាម នៅភូមិជីនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយអាហារសម្រាប់ស្រាយបួសចែកជូនបងប្អូនសាសនិកឥស្លាមចំនួន២៥០គ្រួសារ និងអំណោយរបស់សមាគមប្រភពល្អកម្ពុជា ជូនលោកគ្រូ អ្នកគ្រូចំនួន២៥០

គ្រួសារ ដោយក្នុងមួយគ្រួសារទទួលបាន៖ អង្ករ២៥គីឡូក្រាម ផ្លែល្មើ២ប្រអប់ ទឹកដោះគោ២កំប៉ុង ស្ករ-ស២គីឡូក្រាម ប្រេងឆា១ដប ទឹកត្រី១ដប និងអំបិល១គីឡូក្រាម នៅភូមិអង្គរជា ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយអាហារសម្រាប់ស្រាយបួសចែកជូនបងប្អូនប្រជាពលរដ្ឋសាសនិកឥស្លាមចំនួន២០០គ្រួសារ របស់សប្បុរសជន SMG ជូនប្រជាពលរដ្ឋ ក្នុងមួយគ្រួសារទទួលបាន៖ ទឹកក្រូច១ដប ទឹកដោះគោ២កំប៉ុង ស្ករ-ស១គីឡូក្រាម ប្រេងឆា១ដប ទឹកត្រី១ដប និងទឹកស៊ីអ៊ីវ១ដប ក្នុងឱកាសខែស្រាយបួសរ៉ាម៉ាឌន នៅស្រុកកោះសូទិន ខេត្តកំពង់ចាម នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីសូត្រមន្តចូលឆ្នាំថ្មីឆ្នាំថោះ ក្នុងសាលាបឋមសិក្សាកន្ទុយវៃ ព្រមចែកក្រមាដល់លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋក្នុងម្នាក់ៗចំនួន១ និងចូលបច្ច័យបុណ្យមួយចំនួន នៅខេត្តស្វាយរៀង នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំគ្រួសអំពីតួនាទី ភារកិច្ច របស់ក្រុមប្រឹក្សាឃុំ និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៅភូមិគ្រោគ ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី៧ ខែមេសាឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីប្រជុំបូកសរុបរបាយការណ៍ការងារប្រចាំឆ្នាំ២០២២ និងទិសដៅភារកិច្ចឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣។

-រៀបចំពិធីបង្សុកូលតាមទំនៀមទម្លាប់ខ្មែរ និងតាមគន្លងព្រះពុទ្ធសាសនា ដើម្បីសុំសេចក្តីសុខ សេចក្តីចម្រើន សិរីសួស្តី ព្រមទាំងឧទ្ទិសកុសលផលបុណ្យជូនដល់ដួងវិញ្ញាណក្ខន្ធមាតា បិតា ញាតកាទាំងប្រាំពីរសន្តាន ដើម្បីចូលរួមអមអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ និងបាននាំយកគ្រឿងបរិក្ខារ បច្ច័យមួយចំនួនសម្រាប់ប្រគេនព្រះសង្ឃគង់ចាំព្រះវស្សានៅវត្តព្រៃយាយ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង នាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ដឹកនាំក្រុមការងារចុះជួសជុលផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ៥៦ ទៅផ្លូវជាតិលេខ៥៨ ប្រវែង២៤គ.ម ដើម្បីឱ្យបងប្អូនប្រជាពលរដ្ឋ មានភាពងាយស្រួលក្នុងការធ្វើដំណើរ និងការដឹកជញ្ជូនដំណាំកសិផលផ្សេងៗ នៅឃុំស្លក្រាមស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២០ ខែមេសាឆ្នាំ២០២៣។



-ជួបសំណេះសំណាលលោកនាយក នាយិកា និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសាលប្រជុំរបស់ការិយាល័យអប់រំស្រុក ព្រមទាំងឧបត្ថម្ភសារុងម្នាក់មួយ ជាអំណោយរបស់ឯកឧត្តមនាយឧត្តមសេនីយ៍ **តៃ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ជូនលោកគ្រូអ្នកគ្រូទាំងក្របខ័ណ្ឌ និងកិច្ចសន្យា ចំនួន៥៥០នាក់ នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីបើក និងបិទការប្រកួតកីឡាទាត់



(ប១៦) នៅវិទ្យាល័យស្វាយចេក ឃុំទ្រាស ស្រុកស្វាយចេក ព្រមទាំងដឹកនាំកម្លាំងចម្រុះចុះជួយជួសជុលផ្ទះបងប្អូនប្រជាពលរដ្ឋ ដែលរងគ្រោះដោយខ្យល់កន្ត្រាក់ និងឧបត្ថម្ភស័ង្កសី និងថវិកាមួយចំនួន នៅភូមិថែង និងភូមិប្រីយ៍ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមរំលែកទុក្ខគ្រួសារសពលោក **លី ឆាន** នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣។

❈លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមប្រជុំពង្រឹងការងារព្រះពុទ្ធសាសនាក្នុងខណ្ឌពោធិ៍សែនជ័យ នៅវត្តជម្ពូវ័ន ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលលើកទី២ ប្រចាំខែមីនា ឆ្នាំ២០២៣ ជាមួយយុវជន យុវនារី ភូមិ៤ និងភូមិ៥ ក្នុងសង្កាត់ផ្សារដើមថ្កូវ និងឧបត្ថម្ភថវិកាមួយចំនួនរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលាសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នារសៀលថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមប្រជុំពិភាក្សាការងារមូលដ្ឋានសង្កាត់ផ្សារដើមថ្កូវ នៅសាលប្រជុំនាយកដ្ឋានពេទ្យការងារ រាជធានីភ្នំពេញ នារសៀលថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីចម្រើនព្រះបរិត្ត ប្រសិទ្ធិពរជ័យ សិរីសួស្ដីជ័យមង្គល វិបុលសុខ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ នៅរាជធានីភ្នំពេញ នារសៀលថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងបុគ្គលិកសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ នៅមជ្ឈមណ្ឌលកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសំណេះសំណាល និងពិសាអាហារសាមគ្គីមហាគ្រួសារសហគ្រាសធុនតូច មធ្យម និងសិប្បកម្មកម្ពុជា ក្នុងឱកាសអបអរសាទរគមន៍ឆ្នាំថ្មី ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ នារសៀលថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីបង្សុកូលឧទ្ទិសកុសលដល់ដួងវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ក្នុងរបបពិឃាដ នៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្ត និងបួងសួងសុំពរជ័យសុខចម្រើនគ្រប់ប្រការដល់មាតុភូមិ និងប្រជាជនកម្ពុជា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅសាលារាជធានីភ្នំពេញ នារសៀលថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តម **ទីម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកថវិកាមួយចំនួនប្រគល់ជូនគ្រួសារ នៃសពលោក **វណ្ណា លឹមហេង** ប្រធានឃុំរំលេច ស្រុកស៊ីធរកណ្ដាល នៅគេហដ្ឋានក្នុងភូមិព្រៃពោធិ៍ ឃុំរំលេច ស្រុកស៊ីធរកណ្ដាល



ខេត្តព្រៃវែង នារសៀលថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៤កេសធំ ស្មើនឹងចំនួន២.៧០០តេស្ត និងថវិកាមួយចំនួនផ្តល់ជូនដល់រដ្ឋបាលស្រុក មន្ទីរពេទ្យបង្អែកស្រុក រដ្ឋបាលឃុំទាំង៩ ក្នុងស្រុកពារាំង នៅសាលប្រជុំសាលាស្រុកពារាំង ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល ព្រមទាំងនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៤កេសធំ ស្មើនឹងចំនួន២.៧០០តេស្ត និងថវិកាមួយចំនួនផ្តល់ជូនរដ្ឋបាលស្រុក មន្ទីរពេទ្យបង្អែកស្រុក រដ្ឋបាលឃុំទាំង១១ ក្នុងស្រុកស្វាយអន្ទរ នៅសាលប្រជុំសាលាស្រុកស្វាយអន្ទរ ខេត្តព្រៃវែង នារសៀលថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

❃ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវបេតុងប្រវែង៣២គីឡូម៉ែត និងពិធីបុណ្យបញ្ចុះខណ្ឌសីមា និងឆ្លងសមិទ្ធផលនានា នៅវត្តឥន្ទរិទ្ធី ហៅវត្តបារាយណ៍ ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅភូមិបារាយណ៍ ឃុំឈូក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា ឆ្នាំ២០២៣ និងលើកទិសដៅការងារបន្តរបស់រដ្ឋបាលស្រុកអូររាំងឪ នៅសាលប្រជុំសាលាស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣។



-ជាកិត្តិយសក្នុងពិធីសម្ពោធឆ្លងព្រះវិហារ ឧបដ្ឋានសាលា និងសមិទ្ធផលនានា នៅវត្តអង្គរក្រៅ ក្រោមអធិបតីភាពឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅភូមិព្រៃអង្គរក្រៅ ឃុំជូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងពិធីបើកសង្ក្រាន្តនៅទន្លេស្ងួត ដើម្បីទទួលស្វាគមន៍ទេវតាឆ្នាំថ្មី និងភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ នៅក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដែលមានប្រជាជនចូលរួមប្រមាណ៥.០០០នាក់ នៅភូមិបន្ទាយ-មៀន ឃុំមៀន ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣។

-ជួបគណៈប្រតិភូខេត្តតៃនិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដឹកនាំដោយឯកឧត្តម **ផាម វ៉ាន់តឹន** អភិបាលខេត្តតៃនិញ ដើម្បីអបអរសាទរ និងជូនពរក្នុងឱកាស នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ស្ថិតនៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងពិធីសម្ពោធឧបដ្ឋានសាលា និងសមិទ្ធ-ផលនានា ក្នុងវត្តសោភនារាម (វត្តឥសានមានជ័យ) ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ជា សុផារ៉ា** រដ្ឋ-មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅភូមិឥសានមានជ័យ ឃុំអញ្ចើម ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីបុណ្យគម្រប់៧ថ្ងៃ របស់ឧបាសិកា **យុត ទឹម** ត្រូវជាម្តាយក្មេករបស់ ឯកឧត្តម **ថ្លាង ខុឡារី** សមា-ជិកក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ នៅភូមិដំណាក់ចារ ឃុំអញ្ចើម ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣។

❋នាថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ថុង ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញនាំយកទេយ្យទាន ទេយ្យវត្ថុ ចង្ហាន់ និងប្រគេនថវិកាមួយចំនួនដល់ព្រះសង្ឃគង់នៅវត្តព្រែកស្វាយ ស្ថិតក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

❋នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ជឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលក្រុមប្រឹក្សាឃុំព្រៃចារ និងឃុំផ្តៅជុំ នាយ-ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ស្មៀនឃុំ ប្រធានភូមិ ព្រមទាំងលោកប្រធានក្រុមប្រឹក្សាស្រុកជើងព្រៃ នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម និងនាំយកនូវឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៤កេះធំ ដែលជាអំណោយសម្តេចវិបុលសេនា-ភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ជូនដល់មន្ទីរពេទ្យបង្អែកស្រុកជើងព្រៃ និងបានឧបត្ថម្ភថវិកាមួយចំនួនដល់អង្គពិធី។

❋ឯកឧត្តម **ញ៉ូវ សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធ-សភាបានអញ្ជើញ៖

-ជួបពិភាក្សាការងារជាមួយនឹងលោកប្រធានឃុំ និងក្រុមប្រឹក្សាឃុំសំរោង ដើម្បីពិនិត្យការអនុវត្តផែនការឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៅសាលាស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។

-នាំយកចង្ហាន់ ទេយ្យវត្ថុ ទេយ្យទាន និងគ្រឿងឧបភោគបរិភោគ ព្រមទាំងបច្ច័យកសាងប្រគេនព្រះសង្ឃនៅវត្តចំនួន៣ គឺវត្តភ្នំលាំងត្រាច ក្នុងស្រុកក្រគរ វត្តព្រៃខ្លុង ក្នុងស្រុកភ្នំក្រវាញ និងវត្តកែវវិជ័យ ក្នុងស្រុកកណ្តៀង ខេត្តពោធិ៍-សាត់ នាថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣។

❋ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍ ប្រធានភូមិចំនួន២៦នាក់ និងឧបត្ថម្ភថវិកាមួយចំនួន ព្រមទាំងផ្តល់ឧបករណ៍តេស្តកូវីដ-១៩ ចំនួន១០ប្រអប់ សាលាស្រុកចំនួន៧ប្រអប់ មន្ទីរពេទ្យបង្អែក និងការិយាល័យស្រុកប្រតិបត្តិ ចំនួន៤កេស នៅស្រុកជើង-ព្រៃ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមពិធីបង្សុកូលឧទ្ទិសដល់វិញ្ញាណក្ខន្ធបុព្វការីជនរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ នៅវត្តជើងឆ្នុក ឃុំតាំក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម នារសៀលថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងចូលរួមប្រជុំជាមួយនឹងប្រធានក្រុមការងារ ឃុំ សង្កាត់ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ុន ម៉ាណិត** ប្រធានក្រុមការងារថ្នាក់ជាតិ នៅមន្ទីរខេត្តកំពង់ចាម ខេត្តកំពង់ចាម នាល្ងាចថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣។

❋ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធ-សភាបានអញ្ជើញ៖

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី២៩ និងថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិ

ត្រពាំងរពៅ សង្កាត់ព្រៃត្នោត ក្រុងបូកគោ ខេត្តកំពត នារសៀលថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងបានចូលរួមពិសាអាហារស្រាយបួសជាមួយនឹងបងប្អូនសាសនិកឥស្លាមខេត្តកំពត នៅឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងបានចូលរួមពិសាអាហារស្រាយបួសជាមួយនឹងបងប្អូនសាសនិកឥស្លាមខេត្តកំពត នៅភូមិម៉ាក់ប្រាង ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពប្រជាពរដ្ឋ នៅឃុំស្នឹងកែវ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងចូលរួមពិសាអាហារស្រាយបួសជាមួយនឹងបងប្អូនខ្មែរឥស្លាម ខេត្តកំពត នៅវិហារព្រែកជង្រុក ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ចំនួន៨៥គ្រួសារ ព្រមទាំងបាននាំយកអាហារកញ្ចប់សម្រាប់ស្រាយបួសផ្តល់ជូនពួកគាត់ក្នុងមួយគ្រួសារទទួលបាន អង្ករ១០គីឡូក្រាម មី ស្ករ-ស ទឹកសេរ៉ូ និងទឹកត្រី ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិត្រពាំងរពៅ សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត នាព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ចំនួន៩០នាក់ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅសង្កាត់បឹងទូក ក្រុងបូកគោ ខេត្តកំពត នារសៀលថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣។

❋ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងលោកប្រធានមន្ទីរពេទ្យបង្អែកស្រុកពួក និងសួរសុខទុក្ខអ្នកជំងឺដែលកំពុងសម្រាកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យ នៅខេត្តសៀមរាប នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣។



-នាំយកចង្ហាន់ និងថវិកាមួយចំនួនប្រគេនព្រះពិជ័យរង្សីបណ្ឌិត **ឡាច លាង** ព្រះអនុគណក្រុងសៀមរាប ដើម្បីកសាងសាលាអនុគណក្រុង នៅក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសណ្ឋាគារសុខា ខេត្តសៀមរាប នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលបងប្អូនប្រជាពលរដ្ឋ ព្រមទាំងលោកប្រធានមណ្ឌលសុខភាពឃុំគោកដូង និងសួរសុខទុក្ខអ្នកជំងឺដែលសម្រាកព្យាបាលជំងឺក្នុងមណ្ឌលសុខភាពឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប នៅឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣។



❈នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **សឆ ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និង លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី ១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបុណ្យផ្កាប្រាក់ និង សម្ពោធអគារសាលាអនុគណ នៅវត្តទេពពោធិវង្ស ហៅ វត្តថ្មី ឃុំស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ក្រោម អធិបតិភាពដ៏ខ្ពង់ខ្ពស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។



❈នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ម្ជួខ ប៉ៃយ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញនិមន្ត ព្រះសង្ឃចម្រើនព្រះបរិត្ត និងសម្ដែងធម៌ទេសនានៅក្នុងពិធី បុណ្យផ្កាប្រាក់សាមគ្គី ដើម្បីដង្ហែអង្គផ្កាប្រាក់ឆ្ពោះទៅកាន់ វត្តនាគវ័នគិរីរតនារាម (ហៅវត្តស្រុកតាវែង) ស្ថិតនៅឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី។

❈លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការ ទី៥ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីក្នុងពិធី៖



-សំណេះសំណាលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អាណាព្យាបាលសិស្ស បងប្អូនប្រជាពលរដ្ឋ និងលោក លោកស្រីអភិបាលរងស្រុក លោក លោកស្រីមេឃុំ សមាជិក ក្រុមប្រឹក្សាឃុំ លោក លោកស្រីប្រធាន អនុប្រធានភូមិ ដើម្បីអបអរ សាទរពិធីបើកសង្ក្រាន្តបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ឆ្នាំថោះ ចត្វាស័ក ព.ស.២៥៦៧ នៅឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០២៣។



-ជួបសំណេះសំណាលលោកប្រធានមន្ទីរពេទ្យលោកគ្រូ អ្នកគ្រូពេទ្យនៅមន្ទីរពេទ្យបង្អែកបារាយណ៍សន្ទុក ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ ចត្វាស័ក ព.ស.២៥៦៧ ព្រមទាំងឧបត្ថម្ភទទួល បាន៖ ក្រមា១ និងសារុង១ សរុបក្រមា និងសារុងទាំងអស់ ចំនួន២២០ នៅមន្ទីរពេទ្យបង្អែកបារាយណ៍សន្ទុក ឃុំកំពង់ថ្ម ស្រុកបារាយណ៍ ខេត្តកំពង់ធំ នាថ្ងៃទី៦ ខែមេសា ឆ្នាំ ២០២៣។



-សម្ពោធបណ្ណាល័យ និងសមិទ្ធផលនានានៅវត្តវិហារខ្ពស់ ព្រមទាំងប្រគេនបច្ច័យដល់លោកគ្រូចៅអធិការវត្តមួយ ចំនួនសម្រាប់កសាង នៅភូមិចុងព្រៃ ឃុំកំពង់ស្វាយ ស្រុក កំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៣។

-បើកសង្ក្រាន្តឆ្នាំថ្មីរបស់រដ្ឋបាលស្រុកកំពង់ស្វាយ ខេត្ត កំពង់ធំ ដើម្បីអបអរសាទរទទួលទេវតាឆ្នាំថ្មីក្នុងឱកាស នៃ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ព្រមទាំងប្រគេនបច្ច័យដល់ព្រះគ្រូអនុគណ ស្រុកមួយចំនួន និងរដ្ឋបាលស្រុក នៅវត្តមុនីរង្សី ភូមិស្នោ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី១១



ខែមេសា ឆ្នាំ២០២៣។

❈លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសូត្រមន្ត ក្រុងពាលី និងស្រោចស្រពសុគន្ធវារីប្រគេនព្រះគ្រូ កេសរសីលោហាស់កៅ ព្រះចៅអធិការវត្តឧត្តមមានជ័យសិរីមហាតេជោ (ហៅវត្តជ្រោះជ្រៅ) ក្នុងព្រះជន្មាយុគម្រប់៧៣ និមន្តចូល៧៤ព្រះវស្សា នៅវត្តឧត្តមមានជ័យសិរីមហាតេជោ ឃុំគ្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសមិទ្ធផលនានា នៅវត្តឧត្តមមានជ័យសិរីមហាតេជោ (ហៅវត្តជ្រោះជ្រៅ) ព្រមទាំងនាំយកអំណោយរបស់សម្ដេចប្រធានព្រឹទ្ធសភាមួយចំនួន រួមមាន៖ ឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៥៤ប្រអប់ ស្មើនឹង១.៣៥០តេស្ត ប្រគេនដល់ព្រះចៅអធិការវត្ត និងជូនសំលៀកបំពាក់តាជី យាយជី កុមារា កុមារីម្នាក់១កំប្លេរ និងបងប្អូនពុទ្ធបរិស័ទចំណុះជើងវត្ត ដោយម្នាក់ៗទទួលបានសារ៉ុង១ នៅឃុំគ្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។

-ចុះសួរសុខទុក្ខ និងនាំយកសម្ភារព្រមទាំងថវិកាមួយចំនួនជូនគ្រួសារអ្នកមីងទីទាល់ក្រកំពុងមានជំងឺនៅក្នុងឃុំថ្មដា ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមពិធីសូត្រមន្តបុណ្យបច្ច័យបួន នៅភូមិសាលាលេខ៥ ឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

❈នាថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីរំលឹកគុណគ្រូ និងសង្រ្កាន នៅវិទ្យាល័យសំឡូត



ស្រុកសំឡូត ខេត្តបាត់ដំបង។

❈ឯកឧត្តម **ស្រី ថេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំង ធ្វើបេសកកម្មមនុស្សធម៌ នៃកម្ពុជា ដើម្បីពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុកទ្រាំង ខេត្តតាកែវ នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២។

-រៀបចំពិធីបង្សុកូលតាមទំនៀមទំលាប់ខ្មែរ និងតាមគន្លងព្រះពុទ្ធសាសនា ដើម្បីសុំសេចក្ដីសុខ សេចក្ដីចម្រើន សិរីសួស្ដី ព្រមទាំងឧទ្ទិសកុសលផលបុណ្យជូនដល់ដួងវិញ្ញាណក្ខន្ធមាតា បិតា ញាតកាទាំងប្រាំពីរសន្តាន ដើម្បីចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ និងបាននាំយកគ្រឿងបរិក្ខារ បច្ច័យមួយចំនួនសម្រាប់ប្រគេនព្រះសង្ឃគង់ចាំព្រះវស្សានៅវត្តបុរាណនិវេសន៍ ហៅវត្តប្រាសាទនាងខ្មៅ នៅភូមិចារ ឃុំរៀង ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងសួរសុខទុក្ខកងកម្លាំងប្រដាប់-អាវុធទិសយោធាភូមិភាគទី៤ និងពិនិត្យវឌ្ឍនភាព នៃការសាងសង់ស្តូប ឈ្មោះ ឈ្នះ ភ្នំ២០០ ក្រោមអធិបតីភាពដ៏ខ្ពង់-ខ្ពស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី នៅឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣។



-ចូលរួមរំលែកមរណទុក្ខជាមួយនឹងក្រុមគ្រួសារសព ឧបាសិកា **ញ៉ឹក ចន្ធូ** នៅសង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣។



-នាំយកនូវចង្ហាន់ ទេយ្យវត្ថុជាគ្រឿងឧបភោគ បរិភោគ និងបច្ច័យប្រគេនព្រះសង្ឃគង់នៅវត្តព្រះព្រហ្មរតន៍ ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖



-នាំយកនូវទេយ្យវត្ថុជាគ្រឿងឧបភោគបរិភោគ និងបច្ច័យទៅប្រគេនព្រះសង្ឃគង់នៅវត្តខេមវ័ន្តហៅវត្តខ្សាម ស្ថិតក្នុងភូមិខ្សាម សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ ស្មៀន ប្រធាន-ប៉ុស្តិ៍រដ្ឋបាល ប្រធានភូមិទាំង៥ ដើម្បីស្តាប់ស្ថានភាពទូទៅរបស់មូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាក្រាលឥដ្ឋការ៉ូ នៅសាលាបឋមសិក្សាព្រៃគ្រីជើង នៅឃុំព្រៃគ្រី ស្រុកជល-គិរី ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីប្រកាសសេចក្តី-សម្រេចស្តីពី ការកែសម្រួលឡើងវិញសមាសភាពក្រុមប្រឹក្សាស្រុកជលគិរី អំពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារដណ្តើមយកជ័យជម្នះនាពេលខាងមុខនេះ នៅសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នារសៀលថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។



-នាំយកនូវទេយ្យវត្ថុជាគ្រឿងឧបភោគ បរិភោគ និងបច្ច័យប្រគេនព្រះសង្ឃគង់នៅវត្តធម្មវ័ន្ត នៅភូមិត្រពាំង-អញ្ចាញ ឃុំភ្នំក្រាំងដីមាស ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០២២ និង

ទិសដៅភារកិច្ចឆ្នាំ២០២៣ របស់ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចចៅហ្វាវាំងវររៀងជ័យអធិបតី-ស្រីង្គារ **គង់ សំអុល** រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នៅសាលប្រជុំសាលាខេត្តកំពង់ឆ្នាំង នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមជាមួយនឹងមន្ត្រីរាជការ ប្រជាពលរដ្ឋ រៀបចំពិធីសូត្រមន្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ និងពិសារអាហារសាមគ្គី នៅក្នុងបរិវេណសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមពិធីបុណ្យផ្កាប្រាក់ អភិសេកព្រះរូបព្រះនារាយណ៍ និងប្រកាសបើកពិធីសង្ក្រាន្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ នៅស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣។

❋ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ព្រមទាំងនាំយកកន្ត្រៃកាត់សក់ចំនួន៤ឈុត ព្រមទាំងថវិកាមួយចំនួនជូនដល់ក្រុមយុវជនចំនួន៨នាក់ ចុះកាត់សក់ជូនប្រជា-ពលរដ្ឋចំនួន៥៣នាក់ (ស្រី១៧នាក់) និងចែកនំចំណីដល់ក្មេងៗចំនួន៤៤នាក់ នៅក្នុងមូលដ្ឋានភូមិកោះសោម ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកថវិកាមួយចំនួនជូនលោក **ឃិន ណូត** អតីតប្រធានក្រុមប្រឹក្សាស្រុកកំពង់ត្រាច ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ស្ថិតនៅក្នុងភូមិកំពង់ត្រាចទី១ ឃុំកំពង់-ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត នាព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣។



-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពលោក **ម៉ុត សែន** ជំនួយការ (គ.ជ.ប.) និងជាអតីតប្រធានគណៈកម្មការជាតិរៀបចំការបោះឆ្នោតខេត្តកែប នៅគេហដ្ឋានសព ស្ថិតនៅភូមិស្វាយធំ សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។



-សំណេះសំណាលប្រជាពលរដ្ឋចំនួន១០០នាក់ នៅភូមិរបងក្រាស់ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច

ខេត្តកំពត នារសៀលថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣។

-នាំយកទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃចំនួន៣វត្តៈគឺវត្តភ្នំលាវ វត្តគគីរជុំភ្នំខ្វាវ ក្នុងឃុំពងទឹក ស្រុកដំណាក់ចង្អើរ និងវត្តភ្នំសសៀរ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣។

❈ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញៈ

-ចូលរួមក្នុងពិធីសម្ពោធសមិទ្ធផលនានាក្នុងវត្តព្រៃអង្គរក្រៅ នៅភូមិអង្គរក្រៅ ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខ និងផ្ដល់ជូននូវសម្ភារ ថវិកាមួយចំនួនដល់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំដូនតី នៅភូមិរវីលក្រោម ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងចូលរួមលេងល្បែងប្រជាប្រិយជាមួយនឹងប្រជាពលរដ្ឋនៅភូមិស្នាកណ្ដាល ភូមិពោធិ៍ព្រឹក្សកើត និងភូមិពោធិ៍ ព្រឹក្សលិច ក្នុងឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ នាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ញ៉ែម សាម៉ន** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបើកការដ្ឋានលើកកម្រិត និងជួសជុលថែទាំកំណាត់ផ្លូវជាតិលេខ៧៣ ផ្លូវខេត្តលេខ៣៧៧ និង៣៧៧A ប្រវែងសរុប៩៨.៤០៥គីឡូម៉ែត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ស្ថិតក្នុងបរិវេណវត្តសណ្ដាន់ ភូមិសណ្ដាន់ ឃុំសណ្ដាន់ ស្រុកសំបូរ ខេត្តក្រចេះ។

❈នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងាររបស់រដ្ឋបាលខេត្តសៀមរាប ក្រោមអធិតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសាលប្រជុំសាលាខេត្តសៀមរាប។

❈ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញៈ

-ជួបសំណេះសំណាលប្រជាពលរដ្ឋនៅភូមិអន្ទឹតសុខ និងនាំយកអំណោយចែកជូនដល់សមាជិកនៃអង្គពិធី ដោយក្នុងម្នាក់ៗទទួលបានៈ សារុង១ និងថវិកាមួយចំនួន ព្រមទាំងជួបសំណេះសំណាលជាមួយនឹងលោកប្រធានមណ្ឌលសុខភាពឃុំគោកដូង និងចុះសួរសុខទុក្ខអ្នកជំងឺដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យឃុំ និងនាំយកអំណោយទៅប្រគល់ជូនបុគ្គលិកពេទ្យ និងអ្នកជំងឺរួមមានៈ ឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៧ប្រអប់ ទឹកបរិសុទ្ធ៤០យួរ សារ៉ុង និងថវិកាមួយចំនួន នៅឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប នាព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរស្រុកអង្គរធំ ដើម្បីឈ្វេងយល់អំពីការអនុវត្តគោលនយោបាយភូមិ ឃុំសង្កាត់មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចែកជូនអាជ្ញាធរស្រុកអង្គរធំ និងឃុំចំនួន៣០ប្រអប់ នៅស្រុកអង្គរធំ ខេត្តសៀមរាប នាព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារស្រុកអង្គរធំ ដើម្បីបូកសរុបលទ្ធផលការងារប្រចាំខែមេសា ឆ្នាំ២០២៣ និងលើកទិសដៅការងារបន្តក្រោមអធិបតីភាពឯកឧត្តម **ឃុន ឌុធ** ប្រធានក្រុមការងារ នៅស្រុកអង្គរធំ ខេត្តសៀមរាប នារសៀលថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជួបសួរសុខទុក្ខលោកស្រី **នេត សារ៉ែ** សមាជិកាក្រុមប្រឹក្សាស្រុកប្រាសាទបាគង ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិស្ទឹង ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប៕

## សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ

❋នាព្រឹកថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៣ សមាជិកព្រឹទ្ធសភាចំនួន៩រូប បានអញ្ជើញចូលរួមក្នុងពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅបរិវេណប្រាសាទបាយ័ន ខេត្តសៀមរាប។

❋នារសៀលថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន៧រូប បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌន នៃសាសនាឥស្លាមកម្ពុជា លើកទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ រាជធានីភ្នំពេញ។

❋នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា ពុទ្ធាពិសេក និងឆ្លងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវត្តព្រះបារមីវង្គតបូរី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីបើកទិវាជាតិ “វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។

-ចូលរួមពិសាអាហារពេលល្ងាចជាមួយក្រុមសមាជិកព្រឹទ្ធសភា និងវិទ្យាស្ថានសភាអាស៊ី នៅភោជនីយដ្ឋាន Sevensea ផ្លូវទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមពិធីលៀងសាយភោជទទួលគណៈប្រតិភូមកពីប្រទេសចិន ដែលដឹកនាំដោយឯកឧត្តម H.E Nong Rong ជំនួយការរដ្ឋមន្ត្រីក្រសួងការបរទេសចិន នៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមពិធីប្រគល់សញ្ញាបត្រជូនគរុសិស្ស គរុនិស្សិត និស្សិត និងបុគ្គលិកអប់រំជាង២ពាន់នាក់ ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពីវិទ្យាស្ថានជាតិអប់រំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានជាតិអប់រំ នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣។

❋នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញរៀបចំពិធីបង្សុកូលតាមទំនៀមទម្លាប់ខ្មែរ និងតាមគន្លងព្រះពុទ្ធសាសនា ដើម្បីសុំសេចក្តីសុខ សេចក្តីចម្រើន សិរីសួស្តី ព្រមទាំងឧទ្ទិសកុសលផលបុណ្យ ជូនដល់ដួងវិញ្ញាណក្ខន្ធមាតា បិតា ញាតកាទាំងប្រាំពីរសន្តាន ដើម្បីចូលរួមអមអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ និងបាននាំយកគ្រឿងបរិក្ខារ បច្ច័យមួយចំនួនសម្រាប់ប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តដារ ភូមិដារ ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

❋នាថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជីមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២១-២០២២ និងទិសដៅឆ្នាំសិក្សា ២០២២-២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

❋នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជីមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំ មន្ត្រីរាជការ សមាគម សហជិព កម្មករនិយោជិត គ្រូបង្រៀន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ។

❋លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណាថា** សមាជិកា

គណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមៈ



-ក្នុងពិធីក្រុងពាលីដើម្បីសម្ពោធស្ពានអរិយមគ្គ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅភូមិកាលមេឃ ឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ នារសៀលថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣។



-អបអរសាទរពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** សំពៅត្រែលោកត្រែលក្ខណ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅភូមិកាលមេឃ ឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣។



❈នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញបំពេញទស្សនកិច្ចនៅសត្តឃាតដ្ឋានជ្រូក និងរោងចក្រផលិតចំណីអាហាររបស់ក្រុមហ៊ុន ស៊ី.ភី. ខេមបូឌាចំកាត់ ស្ថិតនៅភូមិឈើទាល ឃុំជំពូវន្ត ស្រុកជុំគិរី ខេត្តកំពត។

❈នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកម្មវិធីទិវាពលកម្មអន្តរជាតិ១ឧសភា ខួបអនុស្សាវរីយ៍លើកទី១៣៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មជ្ឈមណ្ឌលសន្និបាតកោះពេជ្រ នាព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣។

❈នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការទីស្នាក់ការស្រុកភ្នំក្រវាញ នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

❈នារសៀលថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រកាសទទួលស្គាល់សមាសភាពសម្ព័ន្ធភាពសង្គមស៊ីវិលដើម្បីសន្តិសុខមនុស្សជាតិ សាមគ្គីភាព និងអភិវឌ្ឍន៍មាតុភូមិកម្ពុជា ព្រមទាំងចូលរួមពិធីទទួលទានអាហារសាមគ្គី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានសម្ព័ន្ធភាពសង្គមស៊ីវិល ដើម្បីសន្តិសុខមនុស្សជាតិ សាមគ្គីភាព និងអភិវឌ្ឍន៍មាតុភូមិកម្ពុជា និងជាប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមាន៧មករា។



❈នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញនាំយកថវិការបស់គណៈកម្មការប្រគល់ជូនឯកឧត្តមបណ្ឌិត **ហេង សុផាឌី** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សម្រាប់ដំណើរការរៀបចំបោះពុម្ពព្រឹត្តិបត្ររបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ស្តីពី កម្រងស្រាវជ្រាវលេខ៥ នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ រាជធានីភ្នំពេញ៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងត្រីមាសទី១ ២០២៣ ព្រមទាំងលើកទិសដៅការងារបន្ត




*ឯកឧត្តម អ៊ុំ សារឹទ្ធ (ឆ្វេង) និងឯកឧត្តម ឡោក ឆាយ អញ្ជើញអធិបតីភាព ក្នុងកិច្ចប្រជុំបូកសរុបប្រចាំខែមីនា និងត្រីមាសទី១*

ព្រឹកថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ ព្រមទាំងលើកទិសដៅការងារបន្ត ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គ-លេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គ-ភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

ក្នុងឱកាសនោះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការ-ងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែមីនា និងប្រចាំត្រីមាសទី១ដើមឆ្នាំ២០២៣នេះថា ថ្នាក់ដឹកនាំ សមា-ជិក សមាជិកាព្រឹទ្ធសភា មានភាពមមាញឹក និងសកម្មលើគ្រប់មុខងាររបស់ព្រឹទ្ធសភា ហើយទទួលបានលទ្ធផលយ៉ាងល្អប្រសើរ។ លទ្ធផលទាំងនោះក៏ផ្ដើមចេញពីការខិតខំប្រឹង-ប្រែងប្រកបដោយវិជ្ជាជីវៈក្នុងការផ្ដល់សេវាគាំទ្រពីគ្រប់អង្គភាពចំណុះអគ្គខាធិការដ្ឋានព្រឹទ្ធសភាផងដែរ។ ស្នាដៃថ្មីមួយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានរួម-ចំណែកនៅក្នុងគណៈកម្មការពិសេស ដើម្បីធ្វើវិសោធន-កម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ត្រូវបានគណៈកម្មាធិការអចិ-ន្ត្រៃយ៍ និងកិច្ចប្រជុំព្រឹទ្ធសភាពិនិត្យ និងអនុម័តជាស្ថាពរសម្រាប់ដំណើរការរបស់ស្ថាប័ន ស្របតាមបរិបទថ្មី ការរីក-





*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងត្រីមាសទី១*

ចម្រើនរបស់ស្ថាប័ន និងប្រទេសជាតិ។ ក្នុងរយៈពេល៣ខែដើមឆ្នាំនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រេចបានលទ្ធផលជាច្រើនក្នុងការផ្តល់សេវាលើមុខងារតំណាងដែលជារដូវកាលសមាជិកព្រឹទ្ធសភាចុះជាប់ជាមួយនឹងមូលដ្ឋានក្នុងដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតសកលនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។ ដោយឡែកមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ នៅតែបន្តយ៉ាងសកម្មភាព និងកិច្ចសហប្រតិបត្តិការឥតឈប់ឈរ ដោយបានចូលរួមមហាសន្និបាតសហភាពអន្តរសភា និងកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក។

ក្នុងខែមីនា ក៏ដូចជាត្រីមាសទី១ ឆ្នាំ២០២៣នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានអនុវត្តការងារសម្រេចបានលទ្ធផលកើនឡើងលើមុខងារទាំង៥ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២២។ លទ្ធផលទាំងនេះជាសូចនាករ នៃការគ្រប់គ្រង ដឹកនាំ និងការខិតខំរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងការបំពេញការងារយកអស់កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតីលើគ្រប់ការដ្ឋានការងារ ស្របតាមផែនការយុទ្ធសាស្ត្ររបស់ព្រឹទ្ធសភារយៈពេល១០ឆ្នាំ (២០២១-២០៣០) សម្រាប់ការអភិវឌ្ឍព្រឹទ្ធសភាឱ្យក្លាយជាសភាទំនើប។

ផ្អែកតាមលទ្ធផលដំបូងក្នុងត្រីមាសទី១ ឆ្នាំ២០២៣នេះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានណែនាំដល់គ្រប់អង្គភាព ត្រូវធានាកំណើនការងារបន្តទៅមុខទៀត ខិតខំពង្រឹងពង្រីកការងារលើគ្រប់វិស័យ និងគ្រប់មុខសញ្ញាឱ្យបានបោះជំហានទៅមុខព្រមៗគ្នា ទន្ទឹមនឹងការខិតខំប្រមែប្រមូលការគាំទ្រពីសភាជាមិត្ត ដើម្បីគាំទ្រដល់ការចាប់ផ្តើមនីតិកាលទី៥។ ជាមួយគ្នានោះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភានឹងបន្តដាក់ចេញវិធានការ និងគោលនយោបាយនានាបន្ថែមទៀត តាមរយៈការចំណាយឱ្យចំគោលដៅការងារសំខាន់ ចាំបាច់ បន្ទាន់ ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផលខ្ពស់ ហើយធានាបាននិរន្តរភាព និងប្រក្រតីភាពក្នុងការអនុវត្តថវិកា ស្របតាមច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ “គណនេយ្យភាពសមិទ្ធកម្ម” គឺជាឧបករណ៍ថ្មី នៃការគ្រប់គ្រងហិរញ្ញវត្ថុ ដែលទាំងអស់គ្នាត្រូវរៀនសូត្រ និងប្រតិបត្តិឱ្យបានរលូន និងត្រឹមត្រូវតាមច្បាប់ជាធរមាន៕

(រូបភាព និងអត្ថបទ៖ គឹម សិទ្ធី)



*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងត្រីមាសទី១*

# ឯកឧត្តម អ៊ុំ សារឹទ្ធ អនុញ្ញាតឱ្យនិស្សិតជ័យលាភីអាហារូបករណ៍អូស្ត្រាលី ចូលជួបសំណេះសំណាល និងទទួលអនុសាសន៍




*ឯកឧត្តម អ៊ុំ សារឹទ្ធ អនុញ្ញាតឱ្យនិស្សិតជ័យលាភីអាហារូបករណ៍អូស្ត្រាលីចូលជួបសំណេះសំណាល*

នាព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យនិស្សិតជ័យលាភីអាហារូបករណ៍របស់រដ្ឋាភិបាលប្រទេសអូស្ត្រាលីចំនួន១៤នាក់ ចូលជួបសំណេះសំណាល និងទទួលអនុសាសន៍ មុននឹងចេញដំណើរទៅសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅតាមសាកលវិទ្យាល័យនានា នៃប្រទេសអូស្ត្រាលី។

ក្នុងនាមសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានអបអរសាទរចំពោះក្មួយៗនិស្សិតទាំង១៤រូប ដែលទទួលបានអាហារូបករណ៍ពីរដ្ឋាភិបាលអូស្ត្រាលី ដើម្បីទៅសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅប្រទេសអូស្ត្រាលី។ នេះជាឱកាសមួយដ៏ល្អប្រសើរក្រៃលែង ដែលក្មួយៗនិស្សិតទទួលបាននូវចំណេះដឹងថ្មីៗ ដើម្បីពង្រឹងសមត្ថភាពខ្លួនសម្រាប់ជាមូលដ្ឋានក្នុងការអភិវឌ្ឍខ្លួនផង និងប្រទេសជាតិផង។

ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានសង្កត់ធ្ងន់ថា រឿងមួយដែលក្មួយៗនិស្សិតចាំបាច់ត្រូវធ្វើគឺ ត្រូវគោរពច្បាប់ប្រទេស ច្បាប់សាលាឱ្យបានខ្ជាប់ខ្ជួន ដើម្បីបង្ហាញអំពីសេចក្តីថ្លៃថ្នូរក្នុងនាមជាកូនខ្មែរឱ្យក្រុមនិស្សិតដែលមកពីបណ្តាប្រទេសនានាបានឃើញ ត្រូវសម្របខ្លួនរៀនរស់នៅ រៀនទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងប្រទេសអូស្ត្រាលី និងនិស្សិតផ្សេងៗទៀតដែលកំពុងសិក្សានៅទីនោះស្រាប់ ព្រមទាំងផ្សព្វផ្សាយអំពីសភាពការណ៍ថ្មីៗ





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*



*ទិដ្ឋភាពរួមក្នុងពិធីសំណេះសំណាល*

ការអភិវឌ្ឍថ្មីៗរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន ដើម្បីទាក់ទាញឱ្យពួកគាត់មកទេសចរណ៍នៅប្រទេសកម្ពុជា។

ឯកឧត្ដម **អ៊ុំ សារឹទ្ធ** បានផ្ដាំផ្ញើដល់និស្សិតទាំងអស់ ទោះបីជាក្មួយៗត្រូវទៅសិក្សានៅសាលាផ្សេងៗគ្នាក៏ពិតមែន ប៉ុន្តែត្រូវចេះសាមគ្គីភាពផ្ទៃក្នុង សហការគ្នា ទំនាក់ទំនងគ្នា និងចេះជួយយកអាសាគ្នាទៅវិញទៅមក ក្នុងនាមជាខ្មែរដូចគ្នា ដូចសុភាសិតខ្មែរយើងពោលថា នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយជាមួយ។

សូមជម្រាបថា រដ្ឋាភិបាលអូស្ត្រាលីបានផ្ដល់អាហារូបករណ៍ Australia Awards Cambodia ដល់និស្សិតនៅកម្ពុជាអស់រយៈពេល២៨ឆ្នាំមកហើយ។ សម្រាប់ឆ្នាំ២០២៣នេះ បេក្ខជនជ័យលាភីសរុបដែលត្រូវបានជ្រើសរើសមានចំនួន ៤៥រូប (នារី២៣រូប) ដោយក្នុងនោះបេក្ខជនចំនួន២រូប បន្តការសិក្សាថ្នាក់បណ្ឌិត និង៤៣រូបបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

គួរបញ្ជាក់ផងដែរថា និស្សិតជ័យលាភីទាំង៤៥រូប នេះ ត្រូវបានចែកចេញជាពីរក្រុម ដោយក្រុមទី១មានចំនួន៣០នាក់ បានចេញដំណើរទៅបន្តការសិក្សានៅក្នុងប្រទេសអូស្ត្រាលីនាដើមខែមករា ឆ្នាំ២០២៣ និងក្រុមទី២ មានចំនួន១៥នាក់ គ្រោងនឹងចេញដំណើរទៅបន្តការសិក្សានៅអំឡុងខែមិថុនា ឆ្នាំ២០២៣ខាងមុខនេះ។

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ រូបភាព៖ គឹម សិទ្ធី)



*ឯកឧត្តម អ៊ុំ សារឹទ្ធ ថតរូបអនុស្សាវរីយ៍ជាមួយនិស្សិតជ័យលាភីអាហារូបករណ៍អូស្ត្រាលី*

## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការពិនិត្យ កែសម្រួលសេចក្តីព្រាងសេចក្តីសម្រេចស្តីពី គោលការណ៍ផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ ដែលមានស្នាដៃឆ្នើម នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលពិសេសជាន់ខាងក្រោម វិមានព្រឹទ្ធសភា។



❈តបតាមការអញ្ជើញរបស់ ឯកឧត្តម **ប៊ួយ វ៉ាន់គឿង** (Bui Van Cuong) អគ្គលេខាធិការរដ្ឋសភាវៀតណាម នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា បំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។



❈នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាកម្ពុជា បានអញ្ជើញចូលជួបសម្តែងការគួរសមជាមួយនឹងឯកឧត្តម **ត្រាន់ ថាញ់មិន** (Tran Thanh Man) អនុប្រធានទី១ នៃរដ្ឋសភាវៀតណាម ព្រមទាំងជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម **ប៊ួយ វ៉ាន់គឿង** (Bui Van Cuong) អគ្គលេខាធិការរដ្ឋសភាវៀតណាម និងជាប្រធានខុទ្ទកាល័យរដ្ឋសភាវៀតណាម។



❈នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាកម្ពុជា និងគណៈប្រតិភូ បានអញ្ជើញទស្សនាវប្បធម៌នៅឈូងសមុទ្រហាឡុង ខេត្តគ័ងនីញ ដែលជាតំបន់ទេសចរណ៍ដ៏សំខាន់របស់វៀតណាម ហើយជាបេតិកភណ្ឌពិភពលោកទទួលស្គាល់ដោយអង្គការ UNESCO។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារសំខាន់ៗចំពោះមុខ និងកំណត់ទិសដៅការងារនាពេលខាងមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមអគ្គលេខាធិការរង អគ្គនាយក អគ្គនាយិកា នៃអគ្គនាយកដ្ឋានទាំង៥ នៅសាលប្រជុំពិសេសវិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ នៅសាលប្រជុំពិសេសកណ្តាល វិមានព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យការងារត្រៀមរៀបចំពិធីកាត់ឫសសីមា និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសមិទ្ធផលនានា និងព្រះវិហារថ្មី នៅវត្តលុម្ពិនីសាលវ័ននារាម ហៅវត្តអូរសោម។



❈នារសៀលថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី អធិការកិច្ច (ជំហានទី២) នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។




❈នារសៀលថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយនឹងលោក Wang Ke ប្រធានមូលនិធិ PEACELAND នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងដំណើរការប្រឡងប្តូរប្រភេទក្របខ័ណ្ឌ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **លឹម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានទទួលជួបសិក្ខាកាមចំនួន៦នាក់ រៀនវគ្គបណ្តុះបណ្តាលអន្តរជាតិ ITP (International Training Program) ស្តីពីបទប្បញ្ញត្តិគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងក្របខ័ណ្ឌប្រជាធិបតេយ្យ ក្នុងឱកាសអញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន គាំទ្រដោយអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា និងស្ថានទូតចិនប្រចាំកម្ពុជា បានរៀបចំកម្មវិធីបាឋកថាស្តីពី អរិយធម៌សកលបង្កើនល្បឿនឆ្ពោះទៅរកសហគមន៍ជោគវាសនារួមនៃមនុស្សជាតិ ក្រោមអធិបតី-ភាពឯកឧត្តម **ម៉ុន ឧុទ្ធា** អគ្គនាយកដ្ឋានសេវាច្បាប់ និងសម្ហហភាពដែនដី ប្រព្រឹត្តទៅនៅសាលសិក្ខាសាលាខាងជើងវិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃចន្ទ ទី១៧ ខែមេសា ឆ្នាំ២០២៣ លោក-ជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកថវិការបស់សម្តេចប្រធានព្រឹទ្ធសភា និងលោកជំទាវ **អ៊ូ សាន** ចំនួន១០.០០០ ដុល្លារ (មួយម៉ឺនដុល្លារអាមេរិក) ជូនកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃអង្គារ ទី១៨ ខែមេសា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បាននាំយកអំណោយជាថវិកា និងគ្រឿងឧបភោគ បរិភោគប្រចាំថ្ងៃ របស់សម្តេចប្រធានព្រឹទ្ធសភា និងលោកជំទាវ ចែកជូនដល់កុមារកំព្រា នៅសមាគមចលនាវប្បធម៌ជាតិ ដើម្បីកុមារកំព្រា កុមារក្រីក្រ ស្ថិតក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។



❈តបតាមសំណូមពរ និងតម្រូវការចាំបាច់របស់វរការពារព្រំដែនលេខ៧០១ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ទេព ចរិយា** អគ្គនាយករង នៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ បាននាំយកអំណោយរបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា ទៅប្រគល់ជូនដល់កងកម្លាំងនគរបាលការពារព្រំដែនកម្ពុជា-ឡាវ នៃវរសេនាតូចការពារព្រំដែនគោកលេខ៧០១ នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបូរីអូរស្វាយ-មានជ័យ ខេត្តស្ទឹងត្រែង។




❈នារសៀលថ្ងៃពុធ ទី១៩ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **លី ឡេង** នាយកខុទ្ទកាល័យអនុប្រធានទី១ ព្រឹទ្ធសភា បានអញ្ជើញនាំយកថវិការបស់ឯកឧត្តមអនុប្រធានទី១ ព្រឹទ្ធសភា និងលោកជំទាវ ចំនួន៥.០០០ដុល្លារ (ប្រាំពាន់ដុល្លារអាមេរិក) ជូនកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា។



❈នារសៀលថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ គណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយលោកស្រី **ម៉ែន ឌឿន** ប្រធានបណ្ណសារដ្ឋាន នៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ បានអញ្ជើញដាក់កូរ៉ោនផ្កាគោរពវិញ្ញាណក្ខន្ធសពលោកស្រី **ខាត់ សារី** អនុប្រធានការិយាល័យឃ្លាំង នៃបណ្ណសារដ្ឋាន នៅភូមិព្រៃស្រោង ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ៕



